131 ជាការពិតណាស់ ពូជណាក៏ដោយត្រូវតែមានដីរបស់វា។ "ដូច្នេះហើយ ទ្រង់ជ្រាបទាំងអស់..." ឃើញទេ ទ្រង់បានដឹងរួចទៅហើយនូវអ្វីដែលនឹង កើតឡើង។ សូមកត់សម្គាល់ព្រះយេស៊ូវមានបន្ទូលម្ដងទៀត អំពីគ្រាប់ពូជ "អ្នកខ្លះបានធ្លាក់លើថ្ម អ្នកខ្លះទៀតចូលដីចម្រុះ។" ឃើញទេ ពីកន្លែងដែល មានបន្លា អញ្ចាញ និងអ្វីៗផ្សេងទៀត វាមិនអាចរីកចម្រើនបាន។ ហើយពូជ ផ្សេងទៀតនៅលើដីល្អ ដីល្អជាដីដែលត្រូវបានគេរៀបចំទុកជាមុនរួចហើយ។

132 មនុស្សទាំងអស់នៅទីនេះ គាត់ដូចជាមាន់ គាត់កំពុងសំលឹងមើលហើយព្យាយាមរក។ គាត់វាយប៉ះចូល*រឿងនេះ*ហើយគាត់វាយប៉ះចូល*រឿងនោះ* ប៉ុន្តែក្រោយមានសម្លេងស្រែកពីស្ថានសួគ៌មួយរំពេច។ គាត់ស្គាល់វាយ៉ាងរហ័ស "នោះជាព្រះបន្ទូលរបស់ព្រះ!" ឃើញទេ គាត់ដឹងដោយសារតែវាមានអ្វីមួយនៅ ក្នុងចិត្តរបស់គាត់ដែលត្រូវបានគេប្រាប់គាត់ បានបង្ហាញដល់គាត់អំពីវា។

133 សូមកត់សម្គាល់ ហោរាអេសាយបានទាយថា "ស្ត្រីព្រហ្មចារីនឹងមានគភ៌" និយាយអីចំឡែកម្លេះ។ តើបុរស—ម្នាក់ដែលមានប្រាជ្ញាអាចនិយាយអញ្ចឹងបានយ៉ាងម៉េច? វាមិនដែលស្ត្រីព្រហ្មចារីណាអាចមានគភ៌បានទេ។ "ស្ត្រីព្រហ្មចារីនឹងមានគភ៌!" ឥឡូវនេះ គាត់មិនបានបារម្ភអំពីការនិយាយវាទេ គាត់គ្រាន់តែនិយាយប៉ុណ្ណោះ។ តើនាងនឹងធ្វើវាបានយ៉ាងម៉េច? មែនហើយ វាមិនមែនជាការងារគាត់

ទេ! គាត់...គ្រាន់តែនិយាយអ្វីដែលព្រះបាននិយាយនឹង ធ្វើវា។ ព្រះបានបង្ហាញឱ្យគាត់ដឹង បានបង្ហាញនិមិត្តទៅគាត់ បានបើកសម្តែងវា ហើយវាជាការត្រឹមត្រូវ។

134 ដូចជាព្រះតែមួយដែលបានប្រាប់ខ្ញុំថានឹងមានទារកតូចកើតមកឲ្យបុរស ម្នាក់ដែលមិនអាចមានកូនបាន ឬមានកូនស្រីបាន។ ដូចរឿងអ្វីៗផ្សេងទៀត វាដូចជាចំឡែកពេលវេជ្ជបណ្ឌិតនិយាយថា "វាមិនអាចទៅរួច!"

135 ប៉ុន្តែនៅពេលដែលព្រះជាម្ចាស់មានបន្ទូលថា "វានឹងកើតឡើង" វាអាស្រ័យលើប្រភេទពាក្យអ្វីដែលបានធ្លាក់ចូលមក ចូរចាំថា ហោរាបានឈរឡើងនៅទីនោះ ហើយព្រះបន្ទូលទ្រង់បានចេញទៅ។

136 ដូចព្រះ នៅក្នុងលោកុប្បត្តិ១ ទ្រង់មានបន្ទូលថា "ចូរឱ្យមានពន្លឺ។ ចូរឱ្យមាន*នេះ*។ ចូរឱ្យមាន*នោះ*។" បានបង្កើតមនុស្សតាមរូបភាពអង្គទ្រង់ តាមរូបភាពរបស់ទ្រង់ ព្រះអង្គបានបង្កើតគេទាំងប្រុសទាំងស្រី ហើយតាំងពីមិន ទាន់មានអ្វីនៅលើផែនដីនេះនៅឡើយ បន្ទាប់មក យើងរកឃើញនៅក្នុងលោកុប្បត្តិជំពូក២ ទ្រង់បានបង្កើតមនុស្សតាមរូបអង្គទ្រង់ គ្មានមនុស្សណាម្នាក់សោះគ្រាន់តែជាដីនិងការបង្កើតផ្សេងទៀត។ តើវាជាអ្វី? វាជាព្រះបន្ទូលរបស់ទ្រង់ ទ្រង់កំពុងតែមានបន្ទូល។ ហើយនៅពេលដែលទ្រង់ បានមានបន្ទូលទ្រង់និយាយថា "ចូរឱ្យមានពន្លឺឡើង" ប្រហែលជាមិនមានពន្លឺ អស់រយៈពេលប្រាំបីរយឆ្នាំ ក្រោយមកប្រហែលជាមិនមានពន្លឺទេ ប៉ុន្តែទ្រង់បាន មានបន្ទូលឲ្យវាមាន! ហើយដរាបណាទ្រង់មានបន្ទូល "ចូរឱ្យមានដើមត្នោត។ ចូរឱ្យមានដើមឈើអុក។ ចូរឱ្យមាន*នេះ*" គ្រាប់ពូជនីមួយៗត្រូវបានបង្កើតនៅ ខាងក្រោមទឹកនោះ។ ត្រឹមត្រូវហើយ។ ហើយនៅរដូវកាល តាមពេល តាមរដូវរបស់វាវាបាននាំផលចេញទៅ! វាមិនអាចបរាជ័យទេ។ វាជាព្រះបន្ទូល របស់ព្រះ។ វាមិនអាចបរាជ័យបានទេ។ វាជាត្រូវបានសម្តែង

137 ឥឡូវ ថ្ងៃមួយ ព្រះបាននិយាយជាមួយមនុស្សទល់មុខគ្នា។ ប៉ុន្តែនៅក្នុងសម័យលោកម៉ូសេ នៅពេលដែលភ្លើងកំពុងធ្លាក់ចុះ ពួកគេបាន និយាយថា "សូមឱ្យព្រះ...អនុញ្ញាតឱ្យលោកម៉ូសេនិយាយវិញ មិនមែនព្រះទេ យើងអាចនឹងត្រូវវិនាស។"

138 ដូច្នេះទ្រង់បានមានបន្ទូលថា "អញនឹងមិននិយាយទៅកាន់ពួកគេដូច្នេះទៀតទេ។ អញនឹងលើកហោរាក្នុងពួកគេឡើង" នោះជារបៀបដែលប្រព័ន្ធរបស់ ព្រះតែងតែមាន។

139 ឥឡូវនេះ មានហោរាម្នាក់កំពុងតែឈរ។ ឥឡូវនេះ គាត់កំពុងស្ថិតនៅក្រោមការបើកសម្តែង គាត់មិនបានគិតអំពីបញ្ញវន្តរបស់គាត់ទេ "ឥឡូវ សូមចាំបន្តិច។ បើខ្ញុំនិយាយអញ្ចឹង អ្នកដឹងទេ មនុស្សនឹងគិតថាខ្ញុំឆ្កួតហើយ។ ឃើញទេ នោះជាបញ្ញារបស់គាត់ នៅទីនោះគាត់កំពុងស្តាប់សាតាំងដូចជានាងអេវ៉ាដែរ។

140 ហើយដរាបណាគ្រូពេទ្យនិយាយថា "អ្នកមិនអាចរស់បន្តបានទេ។ អ្នកមិនអាចជាសះស្បើយបានទេ។ អ្នកមិនអាចធ្វើ*អញ្ចេះ*ឬធ្វើអញ្ចុះ។" ដរាបណាអ្នកស្តាប់វា ពូជនោះនឹងមិនដែលធ្លាក់ចូលទៅក្នុងដីប្រភេទនោះហើយបង្កើតផលល្អបានឡើយ។ វាមិនអាចទេ។ ប៉ុន្តែពេលណាមានអ្វីមួយស្រក់ហែកចេញ ហើយវាធ្លាក់ក្នុងដីនោះ គឺគ្មានអ្វីដែលអាចហែកវាចេញបានទេ។

141 ឥឡូវនេះ មិនថាវាត្រូវការពេលយូរប៉ុណ្ណាទេ វានឹងកើតឡើង។ ឥឡូវនេះទ្រង់មានបន្ទូលថា "ស្ត្រីព្រហ្មចារីនឹងមានគភ៌" តើអ្នកដឹងទេថាវាមានរយៈពេល ៨០០ឆ្នាំហើយមុនពេលដែលរឿងនោះកើតឡើង? ព្រះជាម្ចាស់ទ្រង់ជ្រាបពីស្ត្រីដែលនាងជានរណា ឈ្មោះរបស់នាងជាអ្វី គឺកន្លែងដែលពូជនោះនឹងធ្លាក់ចូល។ តើអ្នកជឿទេ? ប្រាកដណាស់គាត់បានធ្វើមែន! ហើយពីក្នុងផ្ទៃម្តាយធម្មជាតិ បានចេញជាការដ៏អស្ចារ្យ។ ព្រះជាម្ចាស់ទ្រង់ជ្រាបអំពីការនេះ ហើយទ្រង់បានបើកសម្តែងដល់ហោរាស្មោះត្រង់របស់ទ្រង់ ហើយនិយាយព្រះបន្ទូល។ ដោយមិនគិតពីអ្វីដែលគាត់បាននិយាយ។ គាត់មិនដែលព្យាយាមរកមូលហេតុទេ។

142 បើអ្នកព្យាយាមរកមូលហេតុ...តើមានអ្វីបើបុរសនេះ ស្ត្រីនេះឬបុរសម្នាក់អង្គុយនៅទីនេះ ឬនរណាម្នាក់ព្យាយាមវែកញែកថា "ឥឡូវនេះ ខ្ញុំពិការរាប់ឆ្នាំហើយ។ វេជ្ជបណ្ឌិតមានប្រសាសន៍ថា 'គ្មានឱកាសដែលអាចកើតឡើងបានទេ?'" មែនហើយ វាប្រហែលជាគ្មានដូចដែលគាត់បានដឹង ហើយនោះជាការពិត។

143 ប៉ុន្តែបើអ្វីមួយអាចហែកពួកគេចេញ បើដោយព្រះគុណរបស់ទ្រង់។ មិនមែនជាគ្រូអធិប្បាយ ហើយក៏មិនមែនជានរណាផ្សេងទៀតដែរ។ ប៉ុន្តែព្រះអាចដាក់ចូលទៅក្នុងចិត្តរបស់អ្នកពីការបើកសម្តែងនោះថា "ខ្ញុំនឹងមិនអីទេ" គ្មានអ្វីដែលត្រូវរក្សាអ្នកឲ្យអង្គុយនៅទីនោះទេ។ គ្មានអ្វីអាចរារាំងអ្នកនៅទី នោះទេ អ្នកនឹងទៅសុខសប្បាយ! ប៉ុន្តែរហូតទាល់តែរឿងនោះកើតឡើង អ្នកនឹងអង្គុយកន្លែងដែលត្រូវវេជ្ជបណ្ឌិតនិយាយ រហូតដល់វាកើតឡើង។ វាត្រូវតែបង្ហាញឱ្យឃើញ។ វាជាព្រះគុណរបស់ព្រះដែលបង្ហាញវា។

144 ឥឡូវនេះកត់សម្គាល់ព្រះបានដឹងថាស្ត្រីនោះនឹងមកដល់។ សូមកត់សម្គាល់ពីអេសាយគ្មានសំណួរទេ។ អេសាយមិនបាននិយាយថា "ចាំបន្តិចព្រះអម្ចាស់អើយ! តោះ...ចាំបន្តិច! តើអ្នកបាននិយាយមកខ្ញុំថា 'ស្ត្រីព្រហ្មចារីនឹងមានផ្ទៃពោះមែនទេ'? មែនហើយ ឥឡូវនេះរង់ចាំសិន ព្រះវរបិតានៅទីនោះ—នៅទីនោះ—គ្មានរឿងនេះអាចកើតឡើងបានទេ"

145 គាត់មិនស្ទាក់ស្ទើរឡើយគាត់គ្រាន់តែនិយាយថា "ស្ត្រីព្រហ្មចារីនឹងមានផ្ទៃពោះ!" ត្រូវ។

146 សូមកត់សម្គាល់ម៉ារី "ឥឡូវនេះ ព្រះអម្ចាស់សូមរង់ចាំបន្តិច។ អ្នកដឹងខ្ញុំ—ខ្ញុំមិនដែលស្គាល់បុរសណាម្នាក់ផង។ នេះមិនអាចទៅរួចទេ! គ្មានអ្វីដូចនេះកើតឡើងឡើយ! អូហូ អត់ទេ គ្មានរឿងបែបនេះកើតឡើងបានទេ។ តើខ្ញុំនឹងមានកូនដោយរបៀបណា? ខ្ញុំមិនស្គាល់បុរសណាទេ ដូច្នេះវាមិនអាច កើតឡើងទេ! អូ ទេវតាអើយ អ្នកច្រឡំហើយ។ ខ្ញុំមានការបំភាន់ភ្នែក។ អ្នកដឹងទេ ព្រះវិហាររបស់ខ្ញុំនិយាយថា 'ថ្ងៃនេះបានកន្លងផុតហើយ។'" ហ្គាស! វានឹងមិនដែលបានធ្លាក់ចុះនៅក្នុងកន្លែងបែបហ្នឹងទេ។ ម៉ារីមិនដែលសួរសំណួរទេ។

147 នាងបាននិយាយថា "តើវាអាចកើតឡើងយ៉ាងដូចម្ដេចទៅ? ខ្ញុំមិនស្គាល់បុរសណាទេ។

148 ទ្រង់មានបន្ទូលថា "ព្រះវិញ្ញាណបរិសុទ្ធនឹងគ្របបាំងអ្នក។ នោះហើយជារបៀបនឹងកើតឡើង"

149 នាងនិយាយថា "មើល! ខ្ញុំបំរើរបស់ព្រះអម្ចាស់!" គ្មានសំណួរទេ!

150 ឃើញទេ អេសាយ នៅពេលដែលព្រះបង្កើតព្រះបន្ទូលដោយការគិត (ការបើកសម្ដែង) ចូលទៅក្នុងចិត្តរបស់អេសាយ វាបានធ្លាក់ចូលទៅក្នុងទឹកដី ដ៏ត្រឹមត្រូវ វាគឺជាហោរា។ ហោរានោះមិនបានយកចិត្តទុកដាក់ចំពោះប្រាជ្ញារបស់មនុស្សឡើយ។ គាត់មិនខ្វល់អ្វីទាំងអស់ពីបញ្ញាមនុស្ស។ គាត់មិនខ្វល់ពីមនុស្សម្នាក់នោះទេ។ គាត់គឺជាប្រភពនៃព្រះ ហើយពេលព្រះមានបន្ទូល គាត់ក៏និយាយ។ នោះគឺចប់។ មិនថាវាឈឺចាប់ មិនថាវាមិនអាចទៅរួច មិនថាវាស្តាប់មើលទៅដូចឆ្កួតឬអត់វាមិនមែនជារឿងឆ្កួតទេ។ កុំគិតផ្ដេសផ្ដាសចំពោះគាត់។ វាជាព្រះមិនមែនមនុស្សទេ។

151 ហើយនៅពេលដែលព្រះបន្ទូលបានចេញទៅ ឥឡូវនេះវាបានក្លាយទៅជាគ្រាប់ពូជ វាត្រូវតែធ្លាក់នៅកន្លែងណាមួយ។ បើព្រះបានមានបន្ទូល វានឹងនៅក្នុងផ្ទៃនៅកន្លែងណាមួយសម្រាប់វាធ្លាក់ចូលទៅ។ ដូចអ្វីដែលទ្រង់មានបន្ទូល "អ្វីៗទាំងអស់អាចធ្វើទៅបានសំរាប់ពួកគេដែលជឿ។ បើអ្នកនិយាយទៅកាន់ភ្នំនេះថា 'ត្រូវរើចេញ' ហើយជឿដោយមិនសង្ស័យក្នុងចិត្ត អ្នកអាចមានអ្វីដែលអ្នកបាននិយាយ" ឃើញទេ វាត្រូវតែមានកន្លែងណាដែលត្រូវ!

152 សូមកត់សម្គាល់! ឥឡូវនេះយើងឃើញថាអេសាយនៅទីនេះបាននិយាយវា។

153 ស្ត្រីព្រហ្មចារីម៉ារី ដរាបណា...ដីបានរៀបចំរួចហើយ។ នាងនៅតែជាស្រីព្រហ្មចារី។ នាងមិនបាន"ដើរហើរ។" ដីត្រូវបានរៀបចំរួចហើយ ឬតំរូវទុកជាមុនដោយការដឹងមុនរបស់ព្រះ។

154 សូម្បីតែនិយាយថា "នាងគឺជាស្ត្រីព្រហ្មចារី" នៅពេលនោះព្រះជាម្ចាស់ទ្រង់ជ្រាបពីនាងឈ្មោះនាងជាអ្វីរួចហើយ។ ដ្បិតឈ្មោះរបស់នាងគឺនៅក្នុងសៀវភៅជីវិតនៅស្ថានសួគ៌។

155 បន្ទាប់មក វាត្រូវបានបើកសម្តែងការពិត។ បន្ទាប់មកមនុស្ស (ទៅមនុស្ស) បានឃើញការបង្ហាញរបស់វាដោយកិច្ចការនៅពេលដែលវាត្រូវបានធ្វើរួច។ ឥឡូវយើងក្រឡេកមើលទៅក្រោយហើយនិយាយថា "ប្រាកដណាស់វាត្រូវបានធ្វើ" ពីព្រោះយើងឃើញកិច្ចការនោះបានសម្រេចហើយ។

156 ការប្រព្រឹត្តរបស់លោកណូអេបានសម្តែងដល់មនុស្ស ពីសេចក្តីជំនឿរបស់គាត់ នៅក្នុងព្រះជាម្ចាស់គឺជាការសន្យា។ ឥឡូវនេះព្រះបានជួបណូអេហើយទ្រង់មាន បន្ទូលថា "ណូអេ នឹងមានភ្លៀងធ្លាក់មក។ អញនឹងបំផ្លាញផែនដីទាំងមូលដោយ ទឹក។" ឥឡូវនេះ វាមិនដែលមានភ្លៀងទេ នោះគឺមិនអាចទៅរួចនោះទេ។ មែនហើយ ឥឡូវនេះ ណូអេមាន...និយាយថា "រៀបចំទូកធំមួយដែលខ្ញុំនឹងប្រាប់អ្នក។" ហើយគាត់គឺជាជាងឈើ ហើយគាត់បានទៅធ្វើការនោះ ហើយចាប់ផ្តើមយកជើងរបស់គាត់អ្វីគ្រប់យ៉ាង ដើម្បីកាត់ក្តារនិងជួសជុលវានៅទីនោះជាមួយនឹងជ្រៀកឈើ ហើយដាក់ទីលាននៅក្នុងវាដូចអ្វីដែលគាត់បាននិយាយ។ ហើយតើអ្នកសាកស្រមៃពីអ្វីដែលមនុស្សបានគិតអំពីបុរសនោះទៅមើល?

157 ពួកគេបាននិយាយថា "បុរសនោះពិតជាឆ្កួតណាស់ ពីព្រោះគាត់និយាយថា 'វានឹងមានទឹកចេញពីលើមេឃ' ហើយមើលគ្មានទឹកនៅទីនោះទេ។" ប៉ុន្តែ អ្នកឃើញទេ ណូអេមិនបានគិតអំពីវាទេ។ ការប្រព្រឹត្តរបស់គាត់បានបង្ហាញពីអ្វីដែលជាជំនឿរបស់គាត់និងអ្វីដែលព្រះបាននិយាយថានឹងកើតឡើង។

158 នោះហើយជាហេតុផលដែលគ្រីស្ទានពិតប្រាកដញែកខ្លួនពីអ្វីៗទាំងអស់ តែព្រះបន្ទូល របស់ព្រះមិនថាមនុស្សគិតយ៉ាងណាឬអ្វីដែលនរណាម្នាក់ផ្សេងទៀតនិយាយទេ។ ទ្រង់ញែកពីគ្នាព្រោះ...ទ្រង់មិនគ្រាន់តែមានបន្ទូលទេ បើទ្រង់ធ្វើអញ្ចឹង វាមិនយូរ រហូតដល់ការប្រព្រឹត្តរបស់ទ្រង់នឹងត្រូវបានគេស្គាល់។ ទ្រង់ថយក្រោយហើយក្រឡាស ផ្លូវ*នេះ*ចេញ ហើយចងភ្ជាប់*អានេះ*ជាមួយ*អានោះ*។ ហើយចាប់ផ្ដើម...ទ្រង់នឹង—បង្ហាញថាទ្រង់ជានរណា។ ប៉ុន្តែបើគាត់ជាមនុស្សពិតបើព្រះបន្ទូលរបស់ព្រះ បានចូលទៅក្នុងគាត់ បន្ទាប់មកវានឹងនាំមកនូវផលរបស់វា អ្នកនឹងឃើញបុរស ម្នាក់ដែលកំពុងរៀបចំសម្រាប់ពេលដ៏អស្ចារ្យនោះ។ ឃើញទេ នេះជារបៀបដែល ណូអេបានធ្វើ។

159 លោកម៉ូសេ ជាមួយនឹងដំបងនៅក្នុងដៃរបស់គាត់ បានមកទទួលយកមនុស្សពីផារ៉ោន។ ឥឡូវនេះ តើអ្នកអាចស្រមៃបានទេ...អំពីម៉ូសេ ព្រះគម្ពីរបានចែង ថាគាត់ត្រូវបានបង្ហាត់បង្រៀនដោយប្រាជ្ញាទាំងប៉ុន្មានរបស់ជនជាតិអេស៊ីប។ គាត់ឆ្លាត គាត់អាចបង្រៀនបានរឿងបញ្ញារបស់ពួកគេ។ គាត់ត្រូវបានបង្ហាត់ បង្រៀនតាមប្រាជ្ញារបស់ពួកគេ។ គាត់មិនត្រូវការដើម្បីចាប់យកការអប់រំរបស់ គាត់ទេ។ ឥឡូវនេះ អ្នកគ្រាន់តែគិតអំពីបុរសម្នាក់នៅទីនោះនៅក្នុងទីរហោស្ថាន ជាមួយនឹងការអប់រំទាំងអស់ ហើយបន្ទាប់មកព្រះជាម្ចាស់លេចចេញមក ទ្រង់មានបន្ទូលថា "ម៉ូសេអើយ យកដំបងនេះទៅក្នុងដៃរបស់អ្នក ហើយចុះទៅ ស្រុកអេហ្ស៊ីប ហើយនាំរាស្ត្រអញចេញជាមួយដំបងនេះដែលឯងមាននៅក្នុងដៃ។ គ្រាន់តែធ្វើអ្វីៗទាំងអស់ជាមួយដំបងនេះ។

160 ឥឡូវនេះ ចុះបើលោកម៉ូសេនឹងនិយាយថា "លោកម្ចាស់ ចាំមួយភ្លែត ខ្ញុំគិតថាខ្ញុំបាននិយាយជាមួយ'អញ' ដ៏អស្ចារ្យ ហើយនិយាយពីភាពអស្ចារ្យដែល ទ្រង់មានបន្ទូល។ តើធ្វើដូចម្ដេចឲ្យលោកិយជឿដែលខ្ញុំនឹងយកឈើកោងចាស់នេះ ដែលខ្ញុំមាននៅក្នុងដៃរបស់ខ្ញុំ ហើយទៅកាន់កាប់កងទ័ពរបស់មនុស្សរាប់លាន នាក់ដែល

ប្រដាប់ដោយអាវុធជាមួយលំពែងអ្នកប្រយុទ្ធ? ហើយខ្ញុំមិនមែនជាអ្នក ប្រយុទ្ធទេ ខ្ញុំគឺជាអ្នកឃ្វាលចៀម។ តើធ្វើដូចម្ដេចខ្ញុំធ្វើអញ្ចឹងកើត?"

161 គ្មានសំណួរទេ! ហេតុអ្វី? ហេតុអ្វី? ដីដែលបានរៀបចំគឺនៅក្នុងចិត្តរបស់គាត់! គាត់គឺជាមនុស្សដែលបានតំរូវទុកជាមុន។ "អំណោយនិងការត្រាស់ហៅគ្មានទេ សម្រាប់ការមិនប្រែចិត្ត។" ព្រះបានប្រាប់អ័ប្រាហាំថាគាត់នឹងធ្វើដូច្នោះ ហើយនៅទីនោះគឺជាដីដែលបានរៀបចំ។

162 ហើយលោកម៉ូសេបានយកដំបងនេះហើយបានចុះនៅទីនោះហើយបាន យកប្រជាជាតិមួយចេញពីប្រទេសមួយ។ នៅពេលដែលគាត់មកជាមួយដំបង នៅក្នុងដៃរបស់គាត់ហើយប្រាប់ផារ៉ោនថា "ចូរអោយពួកគេទៅចុះ!" ព្រះចៅផារ៉ោន បានឃើញកិច្ចការលោកម៉ូសេ ដែលគាត់មានជំនឿលើអ្វីដែលគាត់នឹងធ្វើ ឬព្យាយាមធ្វើ។ គាត់មានជំនឿលើការសន្យារបស់ព្រះដែលបានធ្វើការសន្យា គាត់បានចុះទៅយកជ័យជំនះ។ គ្មានបុរសណាម្នាក់អាចធ្វើដូច្នេះបានទេ ហើយក៏គ្មានបុរសផ្សេងទៀតអាចធ្វើបានដែរ គាត់ត្រូវបានគេតែងតាំងឱ្យធ្វើវា។ ព្រះ បានប្រាប់អ័ប្រាហាំជាមុន ថានោះជាអ្វីដែលនឹងកើតឡើង។ ហើយនៅពេល ពេលវេលានៃការសន្យាជិតដល់ហើយ មានក្មេងប្រុសតូចម្នាក់កើតមកជាកូនដ៏ សមរម្យម្នាក់។ ហើយឪពុកម្ដាយអាំរ៉ាមនិងចូឆេបេប មិនខ្លាចនឹងបញ្ញារបស់ ស្ដេចទេ។ ឃើញទេ មានអ្វីមួយ ដីត្រូវបានរៀបចំរួចហើយ។

163 ឱព្រះជាម្ចាស់អើយ ខ្ញុំសង្ឃឹមថាខ្ញុំនឹងនិយាយទៅកាន់ដីដែលបានរៀបចំ នៅយប់នេះ! បើគ្រាប់ពូជអាចធ្លាក់នៅកន្លែងដែលត្រឹមត្រូវ ហើយវានឹងមានខ្លះ... បើវាមិនមែនទេ វានឹងមិនកើតឡើងទេ។

164 នោះជារឿងដដែល។ "ហេតុអ្វី" អ្នកនិយាយថា "បងប្រុសប្រាណហាំ នោះជាប្រភេទនៃការយកវាទៅឆ្ងាយពីយើង។" បើវាកើតឡើង វាយកវាចេញពី គ្រីស្ទានផងដែរ។ ឃើញទេ អ្នកអាចក្លែងបន្លំអ្វីទាំងអស់។ ប៉ុន្តែបើ...បើវា ពិតជាធ្លាក់ចុះនៅក្នុងព្រះបន្ទូលរបស់ព្រះធ្លាក់នៅក្នុងដីត្រឹមត្រូវ វានឹងចេញជា ប្រភេទរបស់វា។ វាត្រូវតែអញ្ចឹង ពីព្រោះវាជាគ្រាប់ពូជ។

165 ណូអេ...លោកម៉ូសេ ការប្រព្រឹត្តរបស់គាត់បានបង្ហាញជំនឿលើសេចក្ដីសន្យារបស់ព្រះអម្ចាស់ដែលគាត់បានជឿ។ ផារ៉ោន ដែលជាមនុស្សគ្រាន់តែអាចមើលឃើញ។ តែមិនអាច...គាត់មិនអាចមើលឃើញពីរបៀបដែលលោកម៉ូសេនឹង ធ្វើ

វាទេ ប៉ុន្តែគាត់បានស្គាល់ថាលោកម៉ូសេជឿអ្វីនិងកំពុងនិយាយ រីគាត់នឹងមិនឈរនៅក្នុងវាំងនៅទីនោះជាមួយនឹងដំបងនៅក្នុងដៃរបស់គាត់។ បាននិយាយថា "ដោយដំបងមួយនេះខ្ញុំនឹងនាំប្រជាជាតិចេញពីអ្នក។" បុរសចំណាស់ម្នាក់ អាយុ ៨០ឆ្នាំហើយ មិនមែនជាអត្តពលិកទេ។ ជាបុរសចំណាស់ ស្មារធ្លាក់ចុះ ដៃធ្លាក់ចុះ គាត់ប្រហែលកោងខ្នង សក់ពណ៌ប្រផេះបើគាត់មាន។ ហើយនៅទីនោះជាមួយនឹងដំបងនៅក្នុងរបស់គាត់ ដៃដោយនិយាយថា "ខ្ញុំនឹងយកពួកគេចេញ ចូរឲ្យពួកគេចេញទៅ **នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់**។ ហើយបើអ្នកមិន ធ្វើដូច្នេះទេ ព្រះជាម្ចាស់នឹងកាត់ទោសអ្នក។" អាម៉ែន! ហេតុអ្វី? នោះជា...ឃើញទេ...តើគាត់ខ្លាចទេ? ហេតុអ្វី គ្រាន់តែព្រួញមួយ លំពែងមួយ និងអ្វីផ្សេងទៀតនឹងបញ្ចប់។ គាត់គ្មានការភ័យខ្លាចទេ! គាត់បានដឹងកន្លែងដែល គាត់កំពុងឈរ។ បាននិយាយថា "ព្រះនឹងវាយអ្នកផារ៉ោនអើយ" បាទ មែនហើយ។

166 ដ្បិតព្រះបានប្រាប់គាត់ថា "អ្នកនឹងមកភ្នំនេះម្តងទៀត" ហើយគាត់ដឹងថាគាត់នឹងទៅទីនោះ។

167 ហាលេលូយ៉ា! យើងដឹងថាយើងនឹងទៅណាដែរ នៅចុងបញ្ចប់នៃការធ្វើដំណើរ។ ព្រះបានសន្យា! មានដីនៅខាងនាយទន្លេ។ ឥតភ័យខ្លាចក្នុងការធ្វើទីបន្ទាល់របស់អ្នក។ អាម៉ែន។ បើវាត្រូវបានបង្ហាញដល់អ្នក អ្នកគឺមិនខ្លាច អ្នកមិនខ្វល់ទេបើលោកិយទាំងមូល...អ្វីដែលពួកគេនិយាយ អ្នកមិនខ្លាច នៅពេលដែលវាបង្ហាញដល់អ្នកថា "នេះគឺជាសេចក្តីពិតដែលនឹងមកដល់ពីព្រះ" បន្ទាប់មក អ្នកនឹងមិនភ័យខ្លាចឡើយ។ បើមិនដូច្នោះទេ អ្នកមិនអាចជាដីល្អទេ។

168 ដាវីឌ ដោយប្រើខ្សែដង្ហក់របស់អ្នកគង្វាល បានសម្តែងដល់កងទ័ពជនជាតិអ៊ីស្រាអែលទាំងមូល ពីសេចក្តីជំនឿដែលគាត់មាននៅក្នុងព្រះរបស់ពួកគេ។ ឥឡូវនេះ មានកូលីយ៉ាតនៅលើដីម្ខាងទៀត ហើយគាត់បានឈរនៅទីនោះ ហើយបានអួតខ្លួន។ មានមាឌធំជាងលោកដាវីឌរាប់ដង មានម្រាមដៃដប់ បួនអ៊ីញ។ ហើយគាត់គឺជាអ្នកខ្លាំង មាឌធំ ជាយក្សភីលីស្ទីន។ ហើយនៅទីនេះ គឺដាវីឌគាត់ជាមនុស្សតូចជាងគេគាត់ជាមនុស្សតូចតាចណាស់ដែលនៅក្នុងជួរ កងទ័ព។ មនុស្សល្ងិតស្នើរតែមិនអាចប្រើគាត់បានទេ។ ដូច្នេះបងប្អូនរបស់គាត់ នៅខាងក្រៅនៅក្នុងជួរកងទ័ព។ ហើយបន្ទាប់មកកូលីយ៉ាតកំពុងតែអួតខ្លួន។

169 ប៉ុន្តែដាវីឌ ឥឡូវនេះសូមចងចាំ វាត្រូវបានបង្ហាញឱ្យដាវីឌដឹងមុន។ គាត់បានគិតថា "នេះជាកងទ័ពនៃព្រះដ៏មានព្រះជន្មរស់ បានឈរនៅលើទឹកដី របស់គេ ហើយមានពួកភីលីស្ទីនដែលមិនកាត់ស្បែកនៅទីនោះ។" យើងនឹងហៅវា ថា "មហារីក" នៅយប់នេះ យើងនឹងហៅវាថា "ខ្ញិន។"

170 ហេតុអ្វី ដាវីឌមិនមែនជាគូរប្រកួតរបស់គាត់ ក៏គ្មាននៃអាវុធណាមួយ ត្រូវនឹងគាត់ដែរ មិនត្រូវគ្នានឹងគាត់ទេ។ ស្មារបស់បុរសនោះប្រហែលជាដប់ ដប់ពីរហ្វីត គាត់ប្រហែលជាកំពស់ដប់បួន ដប់ប្រាំហ្វីត។ ដូចជាលំពែងប្រៀប ជាមួយម្ទុលតម្បាញ ប្រហែលជាប្រវែងម្ភៃហ្វីត នឹងទទឹងបួនហ្វីត។

171 ហើយដាវីឌបានឈរនៅទីនោះជាមួយនឹងស្បែកតូចមួយ ជាស្បែកពពែ ឬស្បែកចៀម ដោយមានខ្សែពីរកំណាត់ជាប់នឹងវា។ ប៉ុន្តែវាបានបង្ហាញដល់គាត់! ការបើកសម្តែងបានវាយប្រហារគាត់! អាម៉ែន! គាត់បាននិយាយថា "ព្រះដែលយកខ្ញុំចេញពីក្រញាំខ្លាឃ្មុំ ហើយដែលនាំខ្ញុំចេញពីក្រញាំតោផង ទ្រង់នឹងបញ្ជូនជនជាតិភីលីស្ទីនដែលមិនកាត់ស្បែកនោះមកជាយ៉ាងណា? នៅក្នុងដៃរបស់ខ្ញុំ!"

172 បងប្អូនប្រុសរបស់គាត់ អាចសាកសមជាងគាត់ក្នុងការធ្វើវា។ ស្តេចសូល ជាមេបញ្ជាការលើកងទ័ពរបស់គាត់។ ប៉ុន្តែ អ្នកដឹងទេ វាមិនត្រូវបានបង្ហាញដល់ពួកគេទេ។ អាម៉ែន។ នៅទីនោះពួកគេជឿថាព្រះអាចធ្វើបាន វាប៉ុន្តែវាមិនបានបង្ហាញដល់ពួកគេទេ។ ប៉ុន្តែមានគេប្រាប់ដាវីឌអោយដឹង។ ឥឡូវនេះ មានភាពខុសគ្នានៅទីនោះ។ បើវាត្រូវបានបង្ហាញឱ្យអ្នកដឹង បើព្រះនឹងព្យាបាល អ្នក អ្នកនឹងជាសះស្បើយ។ [កន្លែងទទេនៅលើកាសែត—] អ្នកនឹងទទួលបានវា។ ខ្ញុំមិនខ្វល់ពីអ្វីដែលមិនប្រក្រដីជាមួយអ្នកទេ តើមានអ្វីខ្លះ ដែលអាក្រក់ជាងរឿង ដាវីឌ និងកូលីយ៉ាត។ ប៉ុន្តែបើវាបានបង្ហាញដល់អ្នក!

173 ហើយសូមកត់សំគាល់ នៅពេលដែលវាត្រូវបានបង្ហាញដាវីឌមិនភ័យខ្លាចទេ។ គាត់បាននិយាយថា "ថ្ងៃនេះខ្ញុំនឹងកាត់ក្បាលអ្នកហើយ!" អាម៉ែន។ នោះជាព្រះរបស់យើង។ ដោយព្រះគុណ នៅក្នុងពេលវេលាដ៏សំខាន់នោះ នៅពេលដែលការសម្រេចចិត្តត្រូវបានធ្វើឡើង គឺជាព្រះតែមួយដែលបានបង្កើត ព្រះគុណនៅថ្ងៃនោះ ហើយទម្លាក់គ្រាប់ពូជនៃសេចក្តីជំនឿនោះទៅក្នុងក្មេងប្រុស ដែលមើលទៅហាក់ដូចជាតូចនៅក្នុងចិត្តរបស់គាត់។ ហើយព្រះដូចគ្នានៅក្នុង ពេលដ៏សំខាន់នេះ អាចយកស្ត្រីនោះចេញពីកៅអីរុញ។ បុរស*នោះ* ស្ត្រីម្នាក់*នៅទីនេះ* កុមារ...?...

គឺជាគ្រាប់ធញ្ញជាតិនៃសេចក្ដីជំនឿត្រូវបានបង្ហាញ ឱ្យអ្នក បន្ទាប់មក ខ្ញុំមិនខ្វល់ថាតើវាត្រូវការពេលប៉ុន្មានទេ។

174 ឥឡូវនេះសូមកត់សម្គាល់ពីយក្ស ដែលនៅលើផ្នែកម្ខាងទៀត ដែលមិនជឿ។ នឹងជាមហារីក។ គាត់សើចគាត់និយាយថា "តើអញជាឆ្កែឬ? ឯងបញ្ជូនក្មេងមកទីនេះដើម្បីប្រយុទ្ធប្រឆាំងនឹងអញ?" បានបន្តថា "អញនឹងចាក់អ្នកនៅលើចុងលំពែងរបស់អញ ហើយឱ្យបក្សីស៊ីសាច់របស់ឯង។" ហេតុអ្វី គាត់មានអ្វីទាំងអស់សម្រាប់គាត់។

175 ប៉ុន្ដែ អ្នកឃើញទេ ថាមិនបានធ្វើឱ្យដាវីឌរញ្ជួយទាល់តែសោះ។ ហេតុអ្វី? វាត្រូវបានបង្ហាញឱ្យគាត់ដឹង។ គាត់មានជំនឿលើអ្វីដែលគាត់កំពុងធ្វើ។ គាត់ដឹងថាគាត់នឹងទៅធ្វើវា។ ហើយគាត់បានធ្វើវាគឺដោយសារតែវាត្រូវបាន បង្ហាញឱ្យគាត់ ហើយគាត់ដឹងកន្លែងដែលគាត់ឈរ។

176 ហើយបើសិនជាព្រះ មានបន្ទូលទៅកាន់ដួងចិត្តរបស់អ្នកយប់នេះ ថា "អ្នកនឹងមិនត្រូវបានដាក់នៅលើគ្រែនោះទៀតទេ។ អ្នកនឹងមិនទៅទេអង្គុយនៅ លើកៅអីនោះទៀតទេ។ អ្នកនឹងមិនអីទេ" មិនអាចមានអ្វីកើតឡើងទេ សូមផ្លាស់ប្ដូរគំនិតរបស់អ្នកនៅក្នុងជំនឿ។

177 ប៉ុន្ដែរហូតទាល់តែវាបានកើតឡើង រាល់គ្រូអធិប្បាយនៅលើលោកិយ អាចអធិស្ឋាន...ខ្ញុំមិននិយាយថាវាមិនបានជួយអ្នកទេ។ វាលើកទឹកចិត្តអ្នក។ ប៉ុន្ដែរហូតដល់សេចក្ដីជំនឿនោះ...ឃើញទេ អំណាចនៃការព្យាបាលនៅក្នុងអ្នក។ វាមិនមកពីគ្រូអធិប្បាយទេ។ វាកើតមានចំពោះអ្នកតាមរយៈការបើកសម្ដែងនិង ដោយជំនឿ។ "មិនមែនដោយអំណាចទេ មិនមែនដោយចេស្ដាទេ ប៉ុន្ដែគឺដោយវិញ្ញាណខ្ញុំវិញ។" ព្រះទ្រង់មានបន្ទូលថា "វិញ្ញាណរបស់ខ្ញុំដោយព្រះ គុណបានបង្ហាញរឿងនេះដល់អ្នក។" ហើយគ្មានអ្វីដែលអាចយកវាចេញបានទេ។ ដោយជំនឿការបើកសម្ដែង! បន្ទាប់មក ដាវីឌបានបង្ហាញការប្រព្រឹត្តរបស់គាត់...

178 ឥឡូវនេះ ពួកគេមួយចំនួនបាននិយាយថា "ខ្ញុំដឹងថាអ្នកគឺជាមនុស្សកំប្លែង" បងប្រុសរបស់គាត់បាននិយាយថា "អ្នកមកទីនេះដើម្បីមើលការប្រយុទ្ធ។ ឥឡូវអ្នកត្រលប់ទៅកន្លែងពួកគេមើលចៀមវិញភ្លាម។"

179 គាត់បាននិយាយថា "សូមឱ្យខ្ញុំនិយាយទៅកាន់សូលជាឧត្តមសេនីយសិន" អ្នកឃើញទេ?

180 សូលនិយាយថា "កូនប្រុសអើយ ខ្ញុំកោតសរសើរចំពោះភាពក្លាហាន របស់អ្នក ប៉ុន្តែអ្នកឃើញទេ អ្នកមិនមានអ្វីក្រៅពីយុវជនទេ។ ហើយគាត់ជាអ្នក ចម្បាំងតាំងពីគាត់នៅក្មេង គ្មានគូរប្រជែងសម្រាប់គាត់ទេ។

181 គាត់បាននិយាយថា "ខ្ញុំកំពុងមើលថែចៀមរបស់ឪពុកខ្ញុំ..." គាត់អាចពឹងផ្អែកលើអ្វីមួយបាន! អាម៉ែន។ ឱបងប្អូនអើយ! ហើយព្រះដែលជួយសង្គ្រោះព្រលឹងអ្នក តើទ្រង់មិនអាចឲ្យអ្នកជាសះស្បើយពីរាងកាយរបស់អ្នកទេឬ? វាដូចគ្នានឹងបង្ហាញដល់អ្នក ទ្រង់ជាអ្នកព្យាបាលរបស់អ្នកដូចជាព្រះអង្គជាព្រះអង្គសង្គ្រោះរបស់អ្នក។ ឃើញទេ? ប៉ុន្តែវាត្រូវតែបង្ហាញឱ្យដឹងជាមុនសិន វាជាភាពខុសគ្នា។ គាត់មានអ្វីមួយដើម្បីផ្អែកលើជំនឿរបស់គាត់។

182 បាននិយាយថា "នេះមិនដែលកើតឡើងពីមុនទេ"

183 ប៉ុន្តែបានបន្តថា "ព្រះតែមួយដែលបានរំដោះខ្ញុំចេញពីក្រញ៉ាំរបស់សត្វតោ នឹងរំដោះខ្ញុំពីជនភីលីស្ទីនដែលមិនកាត់ស្បែកនោះ។"

"តើដាវីឌដឹងយ៉ាងម៉េច?"

"ខ្ញុំជឿវា។"

"ហេតុអ្វី?"

"វាត្រូវបានបង្ហាញឲ្យខ្ញុំដឹង។" ហើយគាត់បាននិយាយថា...

184 គាត់បានដឹងពីអ្វីដែលគាត់កំពុងនិយាយ។ ព្រោះពេលយក្សបាននិយាយថា "អញនឹងយកសាច់ឯងឲ្យបក្សីស៊ី" គាត់តបថា "ខ្ញុំនឹងកាត់ក្បាលរបស់អ្នកចេញ" មានភាពខុសគ្នា ឃើញទេ។ ហើយគាត់បានធ្វើវា!

185 សាំសុន បានចាប់បាននៅថ្ងៃមួយ (អ្នកយាម) នៅក្នុងវាលស្មៅ ហើយនៅទីនេះមានជនជាតិភីលីស្ទីនមួយពាន់នាក់បានមកឯគាត់។ ហើយគាត់ បានក្រឡេកមើលទៅដីហើយនៅទីនោះមានកូនលាមួយបានស្លាប់ ហើយគាត់ បានចាប់យកគ្រោងឆ្អឹងថ្គាមស្ងួត ហើយវាយលើពួកភីលីស្ទីនទាំងនោះ ដោយវាយដំដាក់លើក្បាលដោយប្រើឆ្អឹងថ្គាមស្ងួតចាស់នៃលាមួយ ហើយតាម ខ្ញុំដឹងគ្មានធ្មេញមួយដែលជ្រុះចេញពីវាផង។ ហើយមួកសុវត្ថិភាពរបស់ជនជាតិ ភីលីស្ទីនប្រ

ហែលជាកម្រាស់មួយអ៊ីញ (ព្រោះពួកគេវាយគ្នាទៅវិញទៅមកជាមួយ ក្លិបសង្គ្រាម នៅគ្រានោះ) ដើម្បីការពារពីការវាយលើក្បាលរបស់ពួកគេ។ ប៉ុន្តែគាត់បានយក ឆ្អឹងថ្គាមមកវាយលើជនជាតិភីលីស្ទីនមួយពាន់នាក់។ ហើយឆ្អឹងថ្គាមមិនទាំងជ្រុះ ធ្មេញមួយផង។ គាត់គ្រាន់តែបន្តវាយពួកគេ ដូចជា*អញ្ចឹង* ពេលពួកគេឡើងមក។ ដូច្នេះ ពួកគេដែលនៅសល់បានរើថ្មចេញ ហើយពួកគេគឺរត់ពីគាត់។ ហេតុអ្វី? គាត់ ជឿវា! ពេលខ្លះ...ប្រាកដណាស់។

186 ខ្ញុំចង់ប្រាប់អ្នកពីការខ្លះ។ ធ្វើការលើចលនានោះ ដែលជំរុញមួយរំពេច ដូច យ៉ូសេ្វបានធ្វើ ដូចជាម៉ារាម៉ាក់ដាឡាននិងអ្នកទាំងអស់នោះបានធ្វើ។ គ្រាន់តែ នៅពេលដែលអ្វីមួយត្រូវបានបង្ហាញដល់អ្នក ចូរចាប់យក។ កាន់ភ្ជាប់ នោះជំរុញ មួយភ្លែត។

187 បាទ វាត្រូវបានគេបង្ហាញទៅគាត់។ គាត់បានទៅជួបមនុស្សរាប់ពាន់នាក់ ទាំងនេះជាពួកភីលីស្ទីន។ ឥឡូវនេះតើអ្នកគិតយ៉ាងណានៅពេលដែលពួក ភីលី ស្ទីនទាំងនោះបាននិយាយថា "ឥឡូវនេះមើលមកនៅទីនោះ កូនបង្គោរតូច។ ដែល មានតែកំពស់ប្រហែលបួនហ្វីតកន្លះប៉ុណ្ណោះ ចាប់ផ្តើមជាមួយ ជាមួយនឹង ដុំគ្រួស តូចចំនួនប្រាំពីរព្យួរលើករ ដូចជាស្លាតូចរបស់ម៉ាក់ ឃើញទេ។ ឡើងមកនៅទីនោះ ជាមួយឆ្អឹងថ្គាមនៃសត្វមួយ។ ហើយមើលមកពួកយើង ពួកយើងគឺជាកងទ័ពដ៏ អស្ចារ្យយ៉ាងណាទៅ! តើវាមិនគួរឱ្យអស់សំណើចណាស់ មែនទេ?" ប៉ុន្តែតើគាត់ កំពុងធ្វើអ្វី? គាត់បានប្រាប់ពួកភីលីស្ទីននូវអ្វីដែល ព្រះជាម្ចាស់បានសំដែងអោយ គាត់ស្គាល់។ គាត់បានចាប់ឆ្អឹងថ្គាមយកទៅ។ នោះហើយជាអ្វីដែលគាត់បាន ដាក់នៅក្នុងដៃរបស់គាត់។ គាត់បានដាក់នៅក្នុង ដៃរបស់គាត់ នោះអ្វីដែលគាត់ ជឿ គាត់អាចធ្វើបាន! ហើយដោយធ្វើដូច្នេះ គាត់ត្រូវបានសម្តែងដល់ពួកភីលីស្ទីន ទាំងនោះ គឺជាអ្វីដែលព្រះបានដាក់នៅក្នុង ចិត្តរបស់គាត់។

188 យ៉ូហានបាទីស្ទបានបង្ហាញជំនឿរបស់គាត់ដោយការប្រព្រឹត្តរបស់គាត់ ហើយពេលគាត់និយាយ "មានម្នាក់នៅក្នុងចំណោមអ្នករាល់គ្នាឥឡូវនេះ" សូម គិតអំពីរឿងនោះ។ យ៉ូហាន ឃើញទេខ្ញុំមានបទគម្ពីរយ៉ូហាន១:២៦។ គាត់បាន និយាយថា...

189 ពួកគេបាននិយាយថា "តើអ្នកនិយាយថា 'ព្រះមែស៊ីនឹងយាងមក?' ហេតុអ្វី" គាត់និយាយថា "ឱមនុស្សអើយ តើមានបញ្ហាអ្វីជាមួយអ្នក? យើងកំពុងស្វែងរកទ្រង់អស់រយៈបួនពាន់ឆ្នាំ។"

190 គាត់បាននិយាយថា "ឥឡូវនេះទ្រង់កំពុងតែឈរនៅ ក្នុង ចំណោម អ្នក ហើយ" ហាលេលូយ៉ា! គឺអញ្ចឹងនៅយប់នេះ! អ៊ូ—ហ៊ូ។

191 គាត់បានបង្ហាញជំនឿរបស់គាត់តាមរយៈការបើកសម្តែងរបស់គាត់ ពីព្រោះវាត្រូវបានបង្ហាញឱ្យដឹងថា...គាត់បានដឹងថាគាត់នឹងធ្វើបុណ្យជ្រមុជទឹកឲ្យព្រះមេស្ស៊ី។ ទ្រង់គឺជាបុរសម្នាក់ អាយុសាមសិបឆ្នាំ។ គាត់បានដឹងថាទ្រង់ ត្រូវតែនៅទីនោះនៅកន្លែងណាមួយ។ គាត់មិនដែលស្គាល់ថាទ្រង់ជានរណាឡើយ ហើយគាត់កំពុងតែឈរនៅខាងស្តាំពួកគេ។ គាត់បាននិយាយថា "មានម្នាក់ឈរ ក្នុងចំណោមអ្នក ជាអ្នកដែលអ្នករាល់គ្នាមិនស្គាល់ ហើយខ្ញុំមិនសក្តិសមនឹងស្រាយខ្សែស្បែកជើងរបស់ទ្រង់ផង ប៉ុន្តែទ្រង់នឹងធ្វើពិធីជ្រមុជអោយអ្នករាល់គ្នាក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ ទ្រង់គង់នៅក្នុងចំណោមអ្នករាល់គ្នាឥឡូវនេះ" គាត់បានសម្តែងវា សេចក្តីជំនឿរបស់គាត់ ដោយសារតែគាត់បានដឹងនៅក្នុងថ្ងៃ របស់គាត់ គឺដើម្បីនិងធ្វើបុណ្យជ្រមុជទឹកអោយព្រះមែស៊ី។ ដូច្នេះ អ្នកឃើញទេ មនុស្សអាចមើលឃើញការបញ្ចេញមតិលើវិធីដែលគាត់កំពុងផ្សព្វផ្សាយ និងរបៀបដែលគាត់កំពុងធ្វើគឺបង្ហាញថាគាត់មានការបើកសម្តែងដ៏ពិតពីព្រះ។

192 ឥឡូវនេះ ដើម្បីបង្ហាញថាវាជាការពិត ដើរចេញពីហ្វូងមនុស្សមក ជាព្រះមេស្ស៊ី គ្រាន់តែជាបុរសវ័យក្មេងធម្មតាម្នាក់ ដែលកំពុងដើរឆ្លងកាត់ទីនោះ ស្លៀកពាក់ដូចបុរសដទៃទៀត។ យ៉ូហានបាននិយាយថា "មើលចុះ មានកូនចៀមនៃព្រះ ដែលដកអំពើបាបចេញពីផែនដី។"

193 "តើអ្នកស្គាល់ទ្រង់យ៉ាងដូចម្តេច?"

194 គាត់បាននិយាយថា "ទ្រង់ដែលបាននិយាយមកខ្ញុំ នៅទីរហោស្ថានថា 'នៅលើនរណាដែលអ្នកបានឃើញព្រះវិញ្ញាណយាងចុះមកលើគាត់ គឺជាអង្គនោះ ហើយដែលនឹងត្រូវធ្វើពិធីជ្រមុជទឹកជាមួយព្រះវិញ្ញាណបរិសុទ្ធ'"

195 ឃើញទេ គាត់បានស្គាល់ទ្រង់ពីព្រោះមានគេសន្មត់ទីសំគាល់មួយពេលនោះ។ (តើអ្នកចាប់បានទេ?) យ៉ូហានបានដឹងប្រហែលជាមួយម៉ោងមុនពីព្រោះគាត់ជាហោរា។ វាត្រូវបានគេបង្ហាញឱ្យគាត់ដឹង ថានៅពេលនោះគាត់ នឹង

ឃើញសញ្ញាមួយ។ ហើយនៅពេលដែលគាត់បានឃើញទីសំគាល់នោះ គាត់បាននិយាយថា "ទ្រង់បានឈរនៅក្នុងចំណោមអ្នករាល់គ្នា" គាត់បានដឹងថា ទ្រង់នៅទីនោះ។

196 អូ ខ្ញុំបានឃើញសញ្ញាថាពេលវេលាចុងក្រោយបានមកដល់ហើយ។ ខ្ញុំឃើញសេចក្ដីសន្យាសម្រាប់សារចុងក្រោយនេះដែលនឹងមកដល់ (កំពុងបើក) ពិតជាដូចបទគម្ពីរបានចែង។ ហើយខ្ញុំដឹងថាពេលវេលាជិតមកដល់ហើយ! ខ្ញុំនិយាយថាដោយគ្មានការស្ទាក់ស្ទើរ។ ខ្ញុំជឿថាវាជិតមកដល់ហើយ ព្រោះខ្ញុំ ឃើញសញ្ញានោះដែលទ្រង់បានចែងថានឹងកើតឡើងមុនពេលនោះ។ វារួចរាល់ក្នុងការកើតឡើងហើយ។

197 យ៉ូហានបានបង្ហាញជំនឿលើអ្វីដែលព្រះបានបង្ហាញដល់គាត់។ ដូច្នេះហើយការប្រព្រឹត្តគឺជាទីបន្ទាល់នៃសេចក្ដីជំនឿ។ នៅពេលពួកគេឃើញអ្នកធ្វើដូចជា អ្នកបានជាសះស្បើយ បន្ទាប់មក ពួកគេនឹងដឹងថាអ្នកមានជំនឿថាអ្នកបានជាសះស្បើយហើយ។

198 តើទីបន្ទាល់និយាយអ្វីខ្លះ? និយាយបែបនេះ "ខ្ញុំមានវាហើយ ព្រោះខ្ញុំបានទទួលការសន្យារបស់ព្រះ។ ឥឡូវនេះវាកំពុងធ្វើការនៅក្នុងខ្ញុំ។ ខ្ញុំកំពុងរៀបចំខ្លួនរួចរាល់ហើយដើម្បីឱ្យវាកើតឡើង" អ៊ូ—ហ៊ូ។ ឃើញទេ នោះគឺជាអ្វីដែលទីបន្ទាល់របស់អ្នកធ្វើ។ ល្អហើយ!

199 នៅទីនេះ ពេលខ្លះកាលពីមុន នៅជាប់នឹងដំណើរចុងក្រោយរបស់ខ្ញុំនៅទ្វីប អាហ្វ្រិក។ ខ្ញុំទើបតែចប់នៅនិទាឃរដូវនេះ ប៉ុន្តែធ្វើដំណើរមុនពេលនោះ។ មានទារកតូចមួយដែលមានប្រអប់ជើងនិងជើង...ជើងខ្លីជាងជើងម្ខាងទៀត។ វាមិនដែលពាក់ស្បែកជើងសោះនៅក្នុងជីវិតរបស់វា។ អូវាគឺជាការខូចទ្រង់ទ្រាយដ៏អាក្រក់បំផុត។ ហើយខ្ញុំបានអធិស្ឋានសម្រាប់ទារកនៅយប់នោះ ពួកគេបានមើលឃើញរឿងទាំងនោះ ហើយបានធ្វើការអធិស្ឋានសម្រាប់ទារកនោះ។ ហើយនៅព្រឹកបន្ទាប់ ខ្ញុំបានដើរចុះតាមហាងលក់ស្បែកជើង។ ហើយខ្ញុំបាន ដើរនៅទីនោះ ហើយមានបុរសម្នាក់បានទិញស្បែកជើងឲ្យទារកនោះមួយគូ ដើម្បីពាក់។ គាត់ជឿវា! អ៊ូ—ហ៊ូ។

200 ដូចបុរសម្នាក់នៅទីនេះ ដែលជឿថាព្រះនឹងផ្ដល់ឱ្យគាត់នូវទារក។ ប្រាកដណាស់គាត់ជឿថាវានឹងកើតឡើងគាត់បានរៀបចំខ្លួនរួចជាស្រេច។ "ខ្ញុំត្រៀមខ្លួន

ជាស្រេច" ទោះបីមិនទាន់មានលទ្ធផលជាក់ស្តែងណាមួយ ត្រូវបានគេរកឃើញក៏ដោយ តែវាមិនទាន់មាននៅឡើយទេ ធ្វើឱ្យមានភាពខុសគ្នាបន្តិច។ គាត់បានជឿដូចអ័ប្រាហាំ "បានហៅអ្វីៗទាំងអស់ ផ្ទុយទៅវិញវាហាក់ដូចជាមិនដូច្នោះទេ។ នៅទីនោះ!

201 ដូច្នេះ បើបញ្ញារបស់អ្នកប្រាប់អ្នក...អូ មានភាពវិជ្ជមានឥឡូវនេះ បើបញ្ញារបស់អ្នកប្រាប់អ្នកថា "នេះគឺជាការពិតព្រះជាអ្នកព្យាបាលជំងឺអ្នក" ចិត្តអ្នកអាចធ្វើជាសាក្សីថា "នោះជាព្រះសេចក្តីពិត" ប៉ុន្តែបើមិនមានដីដែល បានរៀបចំនៅក្នុងដួងចិត្តរបស់អ្នក (ជំនឿទៅធ្លាក់ចូល) ដើម្បីបង្ហាញវា វានឹងមិនកើតឡើងទេ។ មិនច្រើនទេ...

មិនថាបុរសខាងក្រៅម្នាក់នេះអាចវែកញែកជាមួយបទគម្ពីរហើយនិយាយថា "វាត្រឹមត្រូវ" ដែលនៅតែមិនធ្វើឱ្យវាត្រឹមត្រូវ។

202 តើមានមនុស្សប៉ុន្មាននាក់ ដែលយកកាសែត? តើអ្នកបានទទួលសេចក្តីអធិប្បាយរបស់ខ្ញុំទេ កាលពីប៉ុន្មានឆ្នាំមុនអ្នកចាក់ប្រេងតាំងនៅថ្ងៃចុងក្រោយ? តើអ្នកជឿទេ? ឃើញទេ វាបាននិយាយថា "នឹងមានអ្នកប្រឆាំងព្រះគ្រិស្ត។ ស្ទើរតែបញ្ឆោតមនុស្សយ៉ាងខ្លាំងបើវាអាចធ្វើទៅបាន" មិនអាចទេ...ប៉ុន្តែមិន អាចទេព្រោះវាមិនអាចទៅរួចទេ។ ពួកគេត្រូវបានជ្រើសរើស។ ឃើញទេ? ត្រឹមត្រូវហើយ។

203 ប៉ុន្តែទ្រង់មានបន្ទូលថា "អ្នកដែលបានចាក់ប្រេងតាំង" ឃើញទេ *ព្រះគ្រីស្ទ*មានន័យថា "ចាក់ប្រេងតាំង" ប៉ុន្តែទាំងនេះគឺអ្នកប្រឆាំង។ ពួកគេត្រូវបានចាក់ប្រេងតាំង ប៉ុន្តែជាអ្នកប្រឆាំង ប្រឆាំងនឹងព្រះគ្រីស្ទនៅក្នុងការ បង្រៀនរបស់ពួកគេ។ ឥឡូវនេះ ពួកគេអាចធ្វើអ្វីដែលអ្នកផ្សេងទៀតក្នុងពួកគេ អាចធ្វើបាន។

204 ឥឡូវ ចាំថា អ្នកស្ថិតនៅក្នុងវដ្តទី៣ ប៉ុន្តែអ្នកជាមនុស្សម្នាក់។ ដូចជាព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ វដ្តនៃមនុស្សបីនាក់ ប៉ុន្តែជាមនុស្សម្នាក់។ បីគុណសម្បត្តិនៃព្រះតែមួយ: ភាពជាឪពុក (បីមុខងារដូចជា) ភាពជាបិតា ភាពជាបុត្រានិងព្រះវិញ្ញាណបរិសុទ្ធ។ ហើយអ្នកគឺជា រាងកាយ វិញ្ញាណ និងព្រលឹង។

205 ឥឡូវនេះ រាងកាយនៅខាងក្រៅមានច្រកចូលប្រាំ ដើម្បីទាក់ទងទៅនឹងផ្ទះនៅផែនដីរបស់អ្នក: ឃើញទេ ការភ្លក់រសជាតិ ការមានអារម្មណ៍ ការដឹងក្លិន និងការ

ស្ដាប់លឺ។ នៅខាងក្នុង ដែលជាវិញ្ញាណ វាមានញ្ញាណទាំងប្រាំ គឺមនសិការនិង សេចក្ដីស្រឡាញ់។ ល។ ប៉ុន្ដែនៅខាងក្នុងនោះ ព្រលឹងមានរឿង មួយ។ នោះជាកន្លែងដែលអ្នករស់នៅ។

206 ព្រះវិញ្ញាណអាចចេញមកនៅទីនេះហើយចាក់ប្រេងតាំងអ្នកដើម្បីធ្វើអ្វីមួយចំនួនហើយអ្នកធ្វើវា ប៉ុន្ដែមិនមែនមានន័យថាអ្នកបានសង្រ្គោះទេ។ គិតពីវា។ កៃផាសបានទាយ។ យូដាសដេញអារក្ស។ ឃើញទេ ព្រះវិញ្ញាណបានចាក់ ប្រេងតាំងគាត់។ ភ្លៀងបានធ្លាក់ទៅលើមនុស្សសុចរិតនិងមនុស្សទុច្ចរិត ស្មៅអាចរីករាយជាមួយស្រូវសាលី។ ប៉ុន្ដែវាជាអ្វីដែលសំខាន់។ នេះជាកន្លែង ដែលអ្នកប្រាជ្ញអាចទទួលយកវា ហើយនិយាយថា "អូប្រាកដណាស់ វាមើលទៅល្អ។ ខ្ញុំជឿ។" វាមិនអញ្ចឹងទេ។ អត់ទេលោក។ ហើយវិញ្ញាណពិត អាចធ្វើបន្ទាល់អំពីវា ហើយនៅតែមិនមែនអញ្ចឹង។ ពីព្រោះបើព្រលឹងនោះមិនមែន មកពីព្រះទេ វាអាចបង្កើតបានតែការក្លែងបន្លំនៅទីនេះ ប៉ុន្ដែវាមិនអាចជាការពិត ទេ។ អ្នកអាចព្យាបាលបាន អ្នកអាចធ្វើដូចជាអ្នកបានធ្វើហើយ។ អ្នកអាចធ្វើដូចជាអ្នកបានទទួលវា។ ពួកគ្រីស្ទានអាចធ្វើដូចជាពួកគេជា គ្រីស្ទានពិត ហើយប៉ិនសម្ដែងទៀត ប៉ុន្ដែនេះមិនមែនមានន័យថាពួកគេត្រូវបាន សង្រ្គោះទេ។ ពិតជាត្រឹមត្រូវមែន។ ព្រះវិញ្ញាណអាចនៅទីនោះដែលជាព្រះវិញ្ញាណ បរិសុទ្ធពិតប្រាកដ។ ព្រះវិញ្ញាណបរិសុទ្ធអាចចាក់ប្រេងតាំងអ្នក តែមិនមែន មានន័យថាអ្នកបានសង្រ្គោះទេ។ វាជាព្រលឹងនៅខាងក្នុងដែលមិនស្លាប់ទទួល បានជីវិតអស់កល្បជានិច្ច។ វាជាជីវិតអស់កល្បជានិច្ច។ ឃើញទេ? វាមកពីព្រះ ហើយទៅឯព្រះវិញ វាជាព្រលឹង។

207 ឥឡូវ សូមកត់សំគាល់ថា វាត្រូវតែជា។ ប្រាំ ជ—ំនេ—ឿ— ខាងក្រៅស្មារតី ព្រះ—យេ—ស៊ូ—វ នៅខាងក្នុង អ្ន—ក។ ឃើញទេ? នោះហើយជារបៀបដែលឈរនៅទីនេះ សម្លឹងមើលទៅអ្នក ខ្ញុំមិនស្គាល់ម្នាក់ណា សោះក្នុងចំណោមអ្នក។ ព្រះវិញ្ញាណអាចចាក់ប្រេងលើខ្ញុំ នៅតែខ្ញុំមិនស្គាល់ នរណាម្នាក់ក្នុងចំណោមអ្នក។ ប៉ុន្ដែនៅពេលដែលផ្នែកខាងក្នុងនៃខាងក្នុងបើក សម្ដែងនោះគឺជាព្រះ។

208 នោះជាកន្លែងដែលខាងក្រៅអាចវែកញែក។ អ្នកយកបុរសម្នាក់ និយាយថា "មែនហើយ អ្នកដឹងទេ ខ្ញុំ—ដឹងថាខ្ញុំមិនគួរប្រព្រឹត្តអំពើផិតក្បត់ទេ។ ប៉ុន្ដែ អ្នកដឹងទេ ពេលនោះវិញ្ញាណប្រាប់ខ្ញុំថាខ្ញុំគួរតែប្រព្រឹត្តអំពើផិតក្បត់ចុះ។ ប៉ុន្ដែ អ្នកឃើញ

ទេ ចុះនៅទីនោះគឺនៅតែមានរឿងនោះ។″ ឃើញទេ វានឹងគ្រប់គ្រងនៅ ជុំវិញចាំតែមើលវាទៅ។

209 ប៉ុន្តែនៅពេលដែលវាត្រូវបានដឹកនាំពីខាងក្នុង វានឹងបោះទៅកន្លែងផ្សេងទៀតជាមួយគ្នា។ នោះជាផ្លូវណែនាំ។ នោះជាប៉មត្រួតពិនិត្យនៅខាងក្នុងនៃខាងក្នុង។ ព្រលឹងគ្រប់គ្រងវិញ្ញាណ វិញ្ញាណគ្រប់គ្រងរាងកាយ។

210 ដូច្នេះការលាងនៅខាងក្រៅមិនមានអ្វីប្លែកទេ។ ពួកគេជាមនុស្សដែលមានជំនឿសាសនានៅទីនោះ ដែលប៉ុលបានហៅថា ″ជញ្ជាំងពណ៌ស″ ជាដើម ពួកគេ (ខាងក្រៅ) គ្រាន់តែជាវិធី...ដែលជាអ្នកជឿ ហើយពួកគេបានទាយក្នុងចំណោមពួកគេនិងអ្វីផ្សេងទៀត ប៉ុន្តែ*នៅខាងក្នុងនៃខាងក្នុង* (″*ព្រលឹង*ដែលមិនគួរជឿ″)

211 នេះជាហេតុផលដែលខ្ញុំនិយាយថា មនុស្សអាចលោតចុះឡើង ហើយនិយាយភាសាដទៃ មនុស្សអាចស្រែកដាក់ដៃលើអ្នកជម្ងឺនិងព្យាបាល អ្នកឈឺជាដើមដោយសេចក្តីជំនឿ អ្វីៗដ៏អស្ចារ្យទាំងអស់នេះដោយព្រះវិញ្ញាណ តែនៅតែបាត់បង់។ ជាអ្នកដែលបានចាក់ប្រេងតាំង។

212 សូមកត់សម្គាល់ព្រះយេស៊ូវមានបន្ទូលថា ″គ្រាន់តែជឿប៉ុណ្ណោះ អ្វីទាំងអស់អាចធ្វើទៅបានដល់ពួកគេដែលជឿ″ ជំនឿនិងការប្រព្រឹត្តគឺជាប្តីប្រពន្ធ ពួកគេធ្វើការជាមួយគ្នា។ ប្តីធ្វើការជាមួយប្រពន្ធ ប្រពន្ធជាមួយប្តី ពួកគេសម្គាល់គ្នាទៅវិញទៅមក។

213 ដូចបុរសនិយាយថា ″គាត់រៀបការរួចហើយ″ ប៉ុន្តែគាត់មិនអាចបង្កើតកូន ឬបង្ហាញបានទេថាគាត់មានប្រពន្ធ អ្នកនឹងសង្ស័យពីការអះអាងរបស់គាត់។ ឃើញទេ? បុរសម្នាក់បាននិយាយថា ″ខ្ញុំរៀបការរួចហើយ។″

តើប្រពន្ធអ្នកនៅឯណា?

″អូ! អូ! ខ្ញុំមិនដឹងទេ″ ឃើញទេ? ឃើញទេ? ជាការលំបាកដែលអោយខ្ញុំជឿគាត់។

ខ្ញុំនិយាយថា ″តើប្រពន្ធរបស់អ្នកនៅឯណា?″

″ខ្ញុំមិនដឹងទេ″ ខ្ញុំ—ខ្ញុំនឹងមិនជឿទេ។

214 ដូច្នេះ អ្នកឃើញទេ បើអ្នកមានអ្វីដែលអ្នកនិយាយថាអ្នកមាន "ខ្ញុំមានជំនឿ" តើធ្វើដូចម្ដេចអ្នកនឹងបង្ហាញខ្ញុំថាអ្នកមានជំនឿ? ដោយការប្រព្រឹត្តរបស់អ្នក។ ឃើញទេ?"

"ខ្ញុំបានរៀបការរួចហើយ"

"តើខ្ញុំដឹងយ៉ាងដូចម្ដេចថាអ្នកបានរៀបការរួចហើយ?"

"នេះគឺជាប្រពន្ធរបស់ខ្ញុំ។" ឃើញទេ? ហ្នឹងហើយ។

"ខ្ញុំបានរៀបការរួចហើយ នេះគឺជាប្ដីរបស់ខ្ញុំ"

"ខ្ញុំបានជាហើយ"

"តើអ្នកដឹងដោយរបៀបណា?"

215 "ការប្រព្រឹត្តរបស់ខ្ញុំបង្ហាញពីជំនឿរបស់ខ្ញុំ" ឃើញទេ? ឃើញទេ? ឥឡូវ តើ—អ្នកនិយាយពីអ្វីជំនឿរបស់អ្នកគឺជាអ្វីដែលព្រះទតឃើញនៅក្នុងអ្នក កិច្ចការរបស់អ្នកគឺជាអ្វីដែលមនុស្សផ្សេងទៀតឃើញនៅក្នុងអ្នក។

216 នោះជាភាព ខុសគ្នារវាងយ៉ាកុបនិងប៉ុលនៅទីនេះ ដោយពន្យល់អំពី អ័ប្រាហាំ។ ពួកគេមិនដែលទាស់ទែងគ្នាទេ ពួកគេទាំងពីរដូចគ្នា រៀបការ។

217 ដូច្នេះគឺជាជំនឿដែលមិនបង្កើតការប្រព្រឹត្ត នរណាម្នាក់មានសិទ្ធិសង្ស័យទីបន្ទាល់របស់អ្នក។ ឥឡូវនេះតើអ្នកឮទេមុនពេលយើងចាប់ផ្ដើមបន្ទាត់អធិស្ឋាន? បើជំនឿរបស់អ្នកមិនបង្កើតការប្រព្រឹត្តជាមួយអ្នកទេ អ្នកមិនអាចធ្វើឲ្យនរណាម្នាក់ជឿបានឡើយថាអ្នកបានជាសះស្បើយហើយ។ និយាយថា "ខ្ញុំមិនដឹងទេ" ឃើញទេ? "ហេតុអ្វី ប្រាកដណាស់ ខ្ញុំមានសេចក្ដីជំនឿទាំងអស់ នៅក្នុងលោកិយ។ អ្នកគ្មានជំនឿទេ។ ពីព្រោះ បើអ្នកមានជំនឿមែន បន្ទាប់មកការប្រព្រឹត្តត្រូវបានរៀបការជាមួយនឹងសេចក្ដីជំនឿ។ ពួកគេជាប្ដីប្រពន្ធមួយ—កំណត់អត្តសញ្ញាណគ្នាទៅវិញទៅមក។

218 សូមគិតអំពីលោកអ័ប្រាហាំពីរបីនាទីទៀត។ អ័ប្រាហាំបានទទួលសហជីពបរិសុទ្ធនៅក្នុងភាពពេញលេញ ឃើញទេគាត់បានទទួលរឿងទាំងមូលជាមួយគ្នា។ គាត់បានហៅអ្វី ដែលផ្ទុយនឹងជំនឿរបស់គាត់ ដូចជាគ្មាន។ ហើយបានធ្វើគោលការណ៍ដូចគ្នា។ ខ្ញុំអាចស្រមៃថា បន្ទាប់ពីប្រហែលម្ភៃឆ្នាំមាន នរណាម្នាក់មកដោយថា៖ "បិតានៃជាតិសាសន៍នានា? ហឺ! លោកអាប់រ៉ាម អ្នកបាននិយាយ

ថាឈ្មោះរបស់អ្នក*អ័ប្រាហាំ* ដែលមានន័យ*បិតាប្រជាជាតិនានា*។ តើអ្នកមានកូនប៉ុន្មាននាក់ហើយឥឡូវនេះ អ័ប្រាហាំ? ឃើញទេ?

219 នោះមិនបានធ្វើឱ្យគាត់ជំពប់ដួលឡើយ។ ព្រះគម្ពីរបានចែងថា "គាត់មិនងឿងឆ្ងល់ទៅឯព្រះបន្ទូលនៃព្រះ តាមរយៈការមិនជឿ" គាត់បានឈានទៅមុខ គាត់បានត្រៀមខ្លួនជាស្រេច ដោយត្រៀមរួចជាស្រេចនិងអ្វីៗទាំងអស់ "ថានឹងមានកូន" ហ្នឹងហើយ។

220 សូម្បីតែសារ៉ាបាននិយាយថា "តើអ្នកដឹងថានឹងមានអ្វីកើតឡើងទេ? អ្នកនឹងមានកូន ប៉ុន្តែខ្ញុំប្រាប់អ្នកពីវិធីដែលយើងនឹងធ្វើវា។ ហាហ្គាតលូវនេះជាអ្នកបំរើរបស់ខ្ញុំ ខ្ញុំនឹងអោយនាងទៅអ្នក។" ពីព្រោះការរៀបការពហុពន្ធភាពគឺស្របច្បាប់។ "នាងនឹងមានកូនហើយខ្ញុំនឹងយកទារកនោះចិញ្ចឹងដោយ ខ្លួនឯង" ប៉ុន្តែអ័ប្រាហាំមិនជឿទេ។ អត់ទេ គាត់នឹងមិនធ្វើវាទេ។ ប៉ុន្តែសារ៉ាត្រូវបានបំផុសគំនិតឱ្យធ្វើវា។

221 ដូច្នេះ ព្រះបានប្រាប់អ័ប្រាហាំថា "ចូរទៅមុខហើយស្តាប់នាងចុះ" ប៉ុន្តែទ្រង់មានបន្ទូលថា "ប៉ុន្តែនេះមិនមែនជាអ្វីដែលអញបានសន្យាជាមួយឯងទេ។" នេះមិនមែនជាវិធីដែលអញបានសន្យាទេ។

222 ឥឡូវនេះ គាត់បានហៅអ្វីដែល "ផុយ" ហើយរាងកាយរបស់គាត់បានស្លាប់ និងស្បូនសារ៉ាដូចគ្នា។ ឥឡូវនេះ គាត់ជាបុរសចំណាស់មួយរយឆ្នាំហើយ។ សារ៉ាមានអាយុកៅសិបឆ្នាំ។ ឥឡូវសូមកត់សម្គាល់! ការស្លាប់ស្បូនរបស់សារ៉ាឬរាងកាយរបស់គាត់មិនដំណើរការ មិនត្រូវបាននាំឱ្យ មានការពិចារណាទេ។

223 ស្តាប់ការនេះ។

*ដ្បិតសេចក្តីសន្យា ដល់លោកអ័ប្រាហាំ និងពូជលោក ឲ្យបានលោកីយ៍ជាមរដក នោះមិនមែនដោយសារក្រឹត្យវិន័យទេ គឺដោយសារសេចក្តីសុចរិតដែលមកដោយសេចក្តីជំនឿវិញ*

*ពីព្រោះបើសិនជាពួកអ្នកដែលអាងក្រឹត្យវិន័យបានគ្រងមរដក នោះសេចក្តីជំនឿបានទៅជាឥតអំពើវិញ ហើយសេចក្តីសន្យាក៏ឥតប្រយោជន៍ដែរ*

*ឯក្រឹត្យវិន័យ នោះបង្កើតសេចក្តីក្រោធ ដ្បិតកន្លែងណាដែលគ្មានក្រឹត្យវិន័យ នោះក៏ឥតមានសេចក្តីរំលងដែល*

224 សូមស្តាប់ ឥឡូវនេះ។

*នរណាប្រឆាំងនឹងក្តីសង្ឃឹម...*

"ប្រឆាំងនឹងសេចក្តីសង្ឃឹម" ក្តីសង្ឃឹមទាំងអស់ត្រូវបានបាត់បង់! អូ រាល់ពេលដែលខ្ញុំមានអារម្មណ៍ "ខៀវ" នេះគឺជាជំពូកដែលខ្ញុំបើកទៅគឺរ៉ូម៤។

*(ដូចមានសេចក្តីចែងទុកមកថា អញបានតាំងឯងឲ្យធ្វើជាឪពុកដល់...សាសន៍ជាច្រើន) រីឯនៅចំពោះព្រះ ជាទីជឿរបស់លោក ដែលទ្រង់ប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ ទាំងមានព្រះបន្ទូលពីរបស់ដែលគ្មាន ទុកដូចជាមានហើយ នោះលោកជាឪពុករបស់យើងមែន។* ("ព្រះមានបន្ទូលអញ្ចឹង!" ឃើញទេ?)

*ដ្បិតកាលលោកអស់ទីសង្ឃឹមហើយ នោះក៏ចេះតែជឿដោយសង្ឃឹមវិញ ដើម្បីឲ្យបានត្រឡប់ជាឪពុកដល់សាសន៍ជាច្រើន ដូចសេចក្តីដែលមានព្រះបន្ទូលទុកមកថា ពូជឯងនឹងបានដូច្នោះ*

225 សូមស្តាប់ខ ១៩ ។

*ហើយដោយព្រោះលោកមិនខ្សោយខាងសេចក្តីជំនឿ បានជាលោកមិនគិតពីរូបកាយលោក ដែលរាប់ដូចជាស្លាប់ ដោយមានអាយុប្រហែលជា១០០ឆ្នាំហើយ ឬពីផ្ទៃសារ៉ា ដែលរាប់ដូចជាស្លាប់ដែរនោះទេ*

*លោកក៏មិនបានសង្ស័យ ចំពោះសេចក្តីសន្យារបស់ព្រះ ដោយចិត្តមិនជឿឡើយ គឺរឹតតែមានសេចក្តីជំនឿខ្លាំងឡើង ទាំងសរសើរដំកើងដល់ព្រះវិញ*

226 នៅអាយុមួយរយឆ្នាំ? មើល សរីរាង្គរបស់គាត់ឥឡូវស្លាប់ហើយ (ភាពជាបុរសរបស់គាត់)និងស្បូនរបស់សារ៉ា។ គាត់... វាមិនត្រូវបានគេគិត សូម្បីតែពេលណាវាបានបង្ហាញដល់គាត់។ គ្រានោះមិនត្រូវបានគេពិចារណាទេ។ អ្នកគឺជាមនុស្សខ្វិន ឬអ្វីក៏ដោយ អ្នកមិនត្រូវបានពិចារណា។ កៅអីរុញមិនស្ថិត នៅក្រោមការពិចារណា

សម្រាប់ក្មេងប្រុសតូចទេ។ អាចពិការ ទោះវាជាអ្វីក៏ដោយ (ខ្ញុំមិនដឹងទេ វាមិនស្ថិតក្រោមការពិចារណាទេ។ កុំគិតពីវា។

227 "ប៉ុន្តែគ្រូពេទ្យបាននិយាយថា 'គាត់នឹងមិនចេញពីទីនេះទេ។' គ្រូពេទ្យបាននិយាយថា 'នាងនឹងមិនមកទេ។'"

228 "មែនហើយ មើល ខ្ញុំជាមនុស្សចាស់ ខ្ញុំមានវ័យពាក់កណ្ដាលហើយ" អត់សូម្បីតែពិចារណាផង។

229 ហើយយើងគឺជាកូនចៅរបស់អ័ប្រាហាំ (ហាលេលូយ៉ា!) មិនមែនដូច ជាអ៊ីសាកទេ ប៉ុន្តែពូជរាជរបស់ទ្រង់ (តាមរយៈព្រះយេស៊ូវគ្រិស្ត) ដោយជំនឿថា គាត់មានពូជរបស់អ័ប្រាហាំចេញមកនៅក្នុងថ្ងៃចុងក្រោយ ដើម្បីឱ្យមានពន្លឺដូចតារា។ កូនចៅអ័ប្រាហាំ! "មិនត្រូវបានគេចាត់ទុកថាជា រាងកាយរបស់គាត់ឥឡូវនេះស្លាប់ទេ" មិនទាំងពិចារណាផង! វាមិនត្រូវបានគេ ចោទសួរទេថាតើព្រះនឹងធ្វើវាឬអត់ ព្រះបានមានបន្ទូលថា ទ្រង់នឹងធ្វើវា! ហេតុអ្វី? វាបានបង្ហាញដល់គាត់។ តើវាត្រូវទេ?

230 នៅពេលដែលវាត្រូវបានបង្ហាញដល់អ្នក នៅពេលដែលវាពិតជាមានអ្វីមួយ... អ្នកមិនអាចធ្វើឱ្យវាកើតឡើងបានទេ វាត្រូវតែបានបង្ហាញឱ្យអ្នក។ បន្ទាប់មកអ្នកធ្វើ ដោយមិនបាច់ពិចារណាអ្វីផ្សេងទៀត តើវាមិនអាចទៅរួចយ៉ាងណា កុំគិតពីអ្វីដែលវេជ្ជបណ្ឌិតបាននិយាយ អ្នកមិនចាំបាច់គិតពីអ្វីដែលម៉ាក់ៗបាន និយាយទេ ឬអ្វីដែលប៉ាៗបាននិយាយ ឬថាអ្វីដែលគ្រូគង្វាលបាននិយាយ តើនរណាខ្លះនិយាយទេ។ អ្នកគ្រាន់តែពិចារណាអ្វីដែលព្រះមានបន្ទូល!

231 "គាត់មិនបានពិចារណាថាសរីរាង្គគាត់បានស្លាប់ ឬស្បូនរបស់សារ៉ាទេ។ វាមិនត្រូវបានគេយកមកពិចារណាទេ។ អូ! ដែលគ្រាន់តែអង្រួនខ្ញុំ។ រាងកាយបាន ស្លាប់និងការស្លាប់នៃស្បូនរបស់សារ៉ា ផ្ទៃមិនបានសូម្បីតែស្ថិតនៅក្រោមការពិចារណា។

232 គ្មានកាលៈទេសៈណានឹងត្រូវពិចារណា ពេលជំនឿបានរកឃើញដីដែល មានជីវជាតិ! នៅពេលដែលហ្សែនពីបុរសបានរកឃើញ—ស៊ុតនៅក្នុងស្ត្រី ហើយពួកគេទាំងពីរមានជីជាតិ មានអ្វីដែលនឹងកើតឡើង។ ហាលេលូយ៉ា! វេជ្ជបណ្ឌិតអាចនិយាយថា "អ្នកនឹងមិនមានកូនទេ។ ខ្ញុំអាចបញ្ជាក់បានថាហ្សែន របស់អ្នកបាន

ស្លាប់នៅក្នុងខ្លួនអ្នក ហើយ—ស៊ុតក៏មិនអាចមានកូនបានដែរ" ប៉ុន្តែសូមឱ្យស៊ុតដែលមានជីជាតិនោះ អនុញ្ញាតឱ្យមេជីវិតនោះបង្វែរខ្លួនវាទៅស៊ុត ពេលមួយមើលតើមានអ្វីកើតឡើង ក្មេងប្រុសតូចឬក្មេងស្រីតូចនោះបានមក។ ហេតុអ្វី? សេចក្តីជំនឿបានរកឃើញដីជីរបស់វា។ កិច្ចការបានសម្រេច កោសិកានៅលើកំពូលនៃកោសិកា ហើយនៅទីនេះបាននាំមកនូវមិត្តតូចមួយ។ អាម៉ែន។ ព្រះ មានសេចក្តីអាណិតមេត្តាយើងខ្ញុំផង។ បពិត្រព្រះអង្គ បើយើងជាគ្រីស្ទានដែលគាប់គួរ បើយើងជាបុរសនិងស្ត្រីដែលអាចទទួលយកព្រះ នៅឯព្រះបន្ទូលរបស់ទ្រង់! អ្នកមិនអាចធ្វើវាបានទេ រហូតដល់វាត្រូវបាន បង្ហាញឱ្យអ្នក។

ខ្ញុំត្រូវប្រញាប់។

233 សូមកត់សម្គាល់ សេចក្តីជំនឿដ៏បរិសុទ្ធរបស់ព្រះបានរួបរួមជាមួយកិច្ចការដ៏ បរិសុទ្ធរបស់ទ្រង់ជាពួកហោរា។ សូមចាំ ថាជំនឿដ៏បរិសុទ្ធរបស់ព្រះត្រូវបានបង្ហាញដល់អ័ប្រាហាំ។ គាត់បានទទួលវា ហើយនៅទីនោះគាត់បានចាប់ផ្តើមជាមួយនឹងការងារដ៏បរិសុទ្ធរបស់គាត់ដោយការជឿ។ គ្រាប់ពូជនៃការសន្យាមាន កន្លែងលូតលាស់។ តើមានអ្វីកើតឡើងបើគាត់បាននិយាយថា (អ័ប្រាហាំ) "មែនហើយ អ្នកដឹងហើយថាសារ៉ាបន្ទាប់ពីនោះគឺវាមានរយៈពេល២៥ឆ្នាំចាប់តាំងពីព្រះបានសន្យាថា"? អូ! "បើមានអ្វីមួយកើតឡើង" ប៉ុន្តែវាគ្មានទេ។ ព្រះជាម្ចាស់ទ្រង់ជ្រាបថាគ្មានទេ។

234 តើមានអ្វីកើតឡើងបើស្ត្រីព្រហ្មចារីម៉ារីបាននិយាយថា "សូមចាំបន្តិច! ស្ត្រី—ព្រហ្មចារីមានផ្ទៃពោះ? អញ្ចឹង ពួកគេនឹងបោះខ្ញុំចេញពីព្រះវិហារបើខ្ញុំចូលទៅនិយាយអញ្ចឹង" ឥឡូវនេះ នាងនឹងគិតគំនិតទាំងនោះបើវាមិនត្រូវបានគេរៀប ចំដីល្អទុកមុន។

235 នៅពេលដែលហោរាបាននិយាយថា "ស្ត្រីព្រហ្មចារីនឹងមានគភ៌។" ឃើញទេ?

236 "ទីសំគាល់ទាំងនេះនឹងធ្វើឲ្យពួកគេជឿ" បើដីល្អត្រូវបានដាក់នៅទីនោះ នៅពេលដែលព្រះបន្ទូលធ្លាក់ចុះនៅទីនោះវាត្រូវរង់ចាំ។ មានគ្មានអ្វីអាចបញ្ឈប់បានឡើយ។

237 ឥឡូវនេះ ប្រញាប់បន្តិច ខណៈពេលដែលយើងបញ្ចប់។ ឃើញទេ ពូជនេះមានកន្លែងដើម្បីលាក់។ ព្រះជាម្ចាស់ទ្រង់ជ្រាប ឬទ្រង់នឹងមិនដែលសន្យា ជាមួយ

អ័ប្រាហាំទេ។ ឥឡូវនេះសូមស្តាប់ ដោយយកចិត្តទុកដាក់។ ព្រះជាម្ចាស់ទ្រង់ជ្រាបពីកន្លែងដែលសេចក្តីសន្យានោះនឹងត្រូវទៅ ទ្រង់មិនដែល ហៅអ័ប្រាហាំរហូតដល់គាត់មានអាយុចិតសិបប្រាំឆ្នាំ ប៉ុន្តែគាត់ជាអ្នកបំរើដែល បានតំរូវទុកជាមុនរបស់ទ្រង់ តាំងពីដំបូងដូច្នេះសារ៉ាក៏ដូច្នេះដែរ។

238 សូមកត់សំគាល់ សូមចងចាំថា គាត់គ្មានព្រះគម្ពីរដែលត្រូវអានទេ។ គាត់គ្មានភាពងាយស្រួលដូចដែលយើងបានអាននៅថ្ងៃនេះ ដើម្បីអានព្រះបន្ទូល របស់ទ្រង់និងមើលអ្នកផ្សេងទៀតដែលបានយកវា។ សូមចាំថា គាត់គ្រាន់តែមាន ការបើកសម្តែង ហើយនោះជារឿងពិត។ ដូចគ្នានឹងយ៉ូសែបដែរ នៅក្នុងលោកុប្បត្តិគ្មានព្រះគម្ពីរទេ។ ចាំថាម៉ូសេបានសរសេរលោកុប្បត្តិ និក្ខមនំ លេវីវិន័យ និងចោទិយកថា។ គ្មានតួអង្គទាំងនោះនៅទីនោះទេ គ្មានព្រះគម្ពីរដើម្បី អានរហូតដល់សម័យលោកម៉ូសេ។ គឺថាត្រូវទេ? ពួកគេគ្មានព្រះគម្ពីរ ដូចយើងមានដើម្បីជួយយើងក្នុងស្ថានភាពពិការ។ ពួកគេជាបុរសដែលមានភាព រឹងមាំដែលត្រូវបានបង្ហាញឱ្យដឹងដោយព្រះ ហើយពួកគេបានឈរនៅទីនោះ។ គ្មានអ្វីផ្លាស់ប្តូរពួកគេទេ។ ឥឡូវនេះ តើអ្នកគិតថាយើងនៅតែមានជំនឿរឹងមាំ? បើវាត្រូវបានបង្ហាញដល់អ្នក!

239 សូមអភ័យទោសចំពោះការបញ្ចេញអារម្មណ៍ ឬទីបន្ទាល់នៅពេលនេះ មុនយើងបិទ។ ខ្ញុំចាំបានថានៅទីនេះក្នុង "ទីក្រុងភ្លោះ" ខ្ញុំគិតថាបងប្រុសប្រោន ហើយពួកគេនៅជាមួយខ្ញុំ។ ហើយខ្ញុំបានយកជីវិតរបស់យ៉ូសែបនៅក្នុងព្រះគម្ពីរ។ ហើយខ្ញុំបានអានព្រះគម្ពីរនោះ មានបុរសម្នាក់គ្មានអ្វីប្រឆាំងទាស់នឹងគេឡើយ! អ័ប្រាហាំ អ៊ីសាក យ៉ាកុប និងពួកគេទាំងអស់មានរឿងទាស់នឹងពួកគេ ប៉ុន្តែមិនមែនយ៉ូសែបទេ។ តើអ្វីទៅ ជាបុរសដ៏ល្អឥតខ្ចោះម្នាក់ គឺជាគំរូដ៏ល្អឥតខ្ចោះរបស់ព្រះគ្រីស្ទ!

240 នៅពេលដែលខ្ញុំបានអាន ខ្ញុំបានយំនៅថ្ងៃមួយនៅក្នុងសណ្ឋាគារតូច ក្នុងបន្ទប់របស់ខ្ញុំ។ ហើយខ្ញុំបានទៅឯក្នុងទូដែលជាកន្លែងដែលខ្ញុំបានព្យួរសម្លៀកបំពាក់របស់ខ្ញុំ ខ្ញុំទាញទ្វារជាមួយគ្នា ហើយខ្ញុំបាននិយាយថា "ព្រះអង្គអើយ ទូលបង្គំចង់អរគុណទ្រង់សម្រាប់មនុស្សដូចយ៉ូសែប ជាមនុស្សម្នាក់ដែលធ្លាប់រស់នៅលើ ផែនដីជាបុរសម្នាក់ដែលមានសាច់ឈាមដូចជាខ្ញុំ ជាបុរសដែលអាចជឿទ្រង់ និងទទួលយកព្រះបន្ទូលរបស់ទ្រង់" គាត់ត្រូវបានបងប្អូនរបស់គាត់ស្អប់។ គាត់មិនអាចជួយខាងវិញ្ញាណបានទេ។ គាត់បានឃើញនិមិត្តមួយ។ គាត់អាចបក

ស្រាយសុបិន។ ពួកគេទាំងអស់ស្អប់គាត់ចំពោះការនោះ។ គាត់មិនអាចជួយប្រាប់ថានោះជាអ្វីដែលគាត់មាន។

241 ឃើញទេ វាមិនមែនជារបស់ផ្សេងទៀតទេ។ ពួកគេគួរតែស្រឡាញ់គាត់ ប៉ុន្តែជំនួសឱ្យការដែលថា...នៅពេលដែលគាត់បានប្រាប់ពួកគេ ពេលខ្លះវាជា អ្វីដែលប្រឆាំងនឹងពួកគេ ពួកគេនិយាយថា "អូ!" នេះគឺជាអាអ្នកពូកែ សុបិនបានមកហើយ។ ឃើញទេ? ហើយពួកគេស្អប់គាត់ដោយគ្មានមូលហេតុ។

242 ខ្ញុំបាននិយាយថា "ហេតុអ្វីពួកគេធ្វើបែបនោះ?" ហើយបុរសនោះមិនដែលរៀចវទ្បើយហើយបន្តនៅទីនោះ។ ឃើញទេ? ខ្ញុំបាននិយាយថា "សូមអរគុណព្រះអម្ចាស់។ ឱព្រះជាម្ចាស់អើយ សូមអរគុណសម្រាប់បុរស បែបនេះ។"

243 នៅពេលនោះព្រះវិញ្ញាណបរិសុទ្ធបានបើកសំដែងមកខ្ញុំថា "អ្នកនឹងមានកូនប្រុសហើយអ្នកនឹងហៅឈ្មោះគាត់ថាយ៉ូសែប។ ខ្ញុំក្រោកពីទីនោះហើយអរគុណព្រះអម្ចាស់។

244 បេកគី កំពុងអង្គុយនៅខាងក្រោយនោះ ទើបតែបានកើតមក...នាងមានអាយុប្រហែលមួយឆ្នាំ។ នាងជាគ្រូពេទ្យវះកាត់ ដែលគ្រប់គ្រងដោយគ្រួសារ ភរិយាខ្ញុំត្រូវបានវះកាត់។ ព្រោះពួកគេមិនស្រឡាំងកាំងដូចស្ត្រីធ្លាប់មានទេឆ្អឹងរឹងដូចបុរស ហើយនាងត្រូវកាត់ចេញពីម្តាយរបស់នាង។ វេជ្ជបណ្ឌិតបាន ប្រាប់ខ្ញុំថា "បងប្រុសប្រាណហាំ អ្នកមិនអាចមានកូនណាម្នាក់ទៀត ដោយសារស្ត្រីនេះទេ។" ក៏បានបន្តថា "ស្បូនរបស់នាងស្តួមដូចប៉េងប៉ោង" គាត់បាននិយាយថា "អ្នកគួរតែអោយខ្ញុំចងបំពង់នោះ។"

245 ខ្ញុំនិយាយថា "អត់ទេ ខ្ញុំនឹងមិន...កុំគិតធ្វើការនោះឲ្យសោះ។"

246 គាត់បាននិយាយថា "អញ្ចឹង អ្នក—អ្នក—អ្នកនឹង...នាងនឹងគ្មានកូនឡើយ។" បានបន្តថា "អ្នកនឹងបំផ្លាញនាង នាងនឹងត្រូវស្លាប់" បាននិយាយថា "យើងមានពេលវេលាអាក្រក់នៅទីនោះ" គាត់ថា" អ្នកទើបតែ...នាងនឹងកើត អញ្ចឹង។

247 ហើយបន្ទាប់មក ព្រះអម្ចាស់បានប្រាប់ខ្ញុំថាខ្ញុំនឹង "មានកូនប្រុសមួយ" ឈ្មោះនោះនឹងត្រូវហៅថា "យ៉ូសែប។" ខ្ញុំមិនដែលខ្លាចអំពីវាទេ។ ទាំងអស់គ្នាចាំបាន។

248 ខ្ញុំបានចេញទៅប្រកាសថា "ខ្ញុំនឹងមានកូន។ ឈ្មោះរបស់គាត់នឹងត្រូវហៅថា យ៉ូសែប" តើមានមនុស្សប៉ុន្មានចងចាំវា? ក្រុមជំនុំនិយាយថា "អាម៉ែ

ន″ មែនហើយ! នៅគ្រប់ទីកន្លែងទូទាំងប្រទេស គ្រប់ទីកន្លែងខ្ញុំប្រាប់មនុស្ស "ថានឹងមានកូន។ ឈ្មោះរបស់គាត់នឹងត្រូវបានហៅថាយ៉ូសែប។″

249 គឺដូចគ្នានឹងក្មេងប្រុសតូចដែលបានរស់ឡើងវិញ នៅក្នុងប្រទេសហ្វាំងឡង់ បងប្រុសជែកគឺនៅទីនោះពេលវាកើតឡើង។ បានប្រាប់អ្នក ពីរឬបីឆ្នាំមុនពេលដែលវាកើតឡើង "នឹងមានក្មេងប្រុសម្នាក់″ តើគាត់ស្លៀកពាក់ យ៉ាងម៉េច កន្លែងដែលគាត់នឹងត្រូវនៅ "ព្រះជាម្ចាស់ទ្រង់មានបន្ទូលដូច្នេះ!″

250 "តើវានឹងកើតឡើងយ៉ាងដូចម្ដេច?″

251 "ខ្ញុំមិនដឹងទេ! ប៉ុន្តែវាត្រូវបានបង្ហាញឱ្យខ្ញុំដឹងថាវាកំពុងដំណើរការកើតឡើង!″

252 វាត្រូវបានបង្ហាញឱ្យខ្ញុំដឹងថា "ខ្ញុំនឹងទៅអារីហ្សូណា ហើយនៅទីនោះខ្ញុំនឹងជួប ទេវតាប្រាំពីរ។ ហើយពួកគេនឹងប្រាប់ខ្ញុំពីសារមួយដែលខ្ញុំបានផ្សព្វផ្សាយ។ នោះគឺជាត្រាទាំង៧។ វាបានកើតឡើង! ប៉ុន្មាននាក់ចាំបានថាខ្ញុំនិយាយដូច្នេះ? ខ្សែអាត់និងរឿងរ៉ាវដែលបានកត់ត្រានោះ។ ហើយវាបានកើតឡើង! ទស្សនាវដ្ដី អ្វីផ្សេងទៀតបានយករូបភាពរបស់វា។ នោះមានពន្លឺនៅលើអាកាស ពួកគេនៅ តែមិនអាចយល់បាននៅឡើយ។ នៅទីនោះ។

253 ខ្ញុំចាំបានថាបានហៅបងប្រុសជេក ហើយសួរគាត់អំពីរឿងនោះ គឺព្រះគ្រីស្ទកំពុងឈរនៅទីនោះ ហើយបងប្រុសជែកបាននិយាយថា នោះគឺនៅក្នុងសិរីល្អរបស់ទ្រង់។ ឃើញទេ? ខ្ញុំស្រឡាញ់បងប្រុសជែក។ គាត់ជាម្នាក់ខាងវិទូល្អ បំផុតដែលខ្ញុំស្គាល់ ប៉ុន្តែខ្ញុំមិនអាចវាយវាបានត្រឹមត្រូវទេ។

254 ខ្ញុំបានឈរនៅទីនោះ ខ្ញុំបាននិយាយថា "ព្រះជាម្ចាស់តើយ៉ាងដូចម្ដេច? យុវជននៅទីនេះ″ខ្ញុំបាននិយាយថា "ជាមួយនឹងសក់ដូចជារោមចៀម″

255 ហើយគាត់បាននិយាយថា "គាត់ត្រូវបានពាក់សក់។″ មើលនៅក្នុងសៀវភៅមុនពេលដែលវាមិនទាន់បានកើតឡើង ខ្ញុំបាននិយាយអញ្ចឹង។ ហើយនៅថ្ងៃនោះនៅពេលដែលបានកើតឡើង វាបានឡើងទៅលើ។ ហើយបន្ទាប់មកអ្នក បង្វែររូបភាពនោះទៅចំហៀង បើអ្នកមានទស្សនាវដ្ដីមើលឬទស្សនាវដ្ដីជីវិត សូមងាកទៅម្ខាង។ នៅទីនោះទ្រង់គឺគ្រាន់តែល្អឥតខ្ចោះ ឥតខ្ចោះនូវគំនូរ របស់ហូមែនព្រះសិរសារបស់ព្រះគ្រិស្ត កំពុងតែសម្លឹងមើលទៅកន្លែងដែលខ្ញុំ កំពុងឈរ។ វាមាននៅក្នុងទស្សនាវដ្ដី! តើមានបងប្អូនប៉ុន្មាននាក់ធ្លាប់បាន ឃើញវា? ពិត

ណាស់អ្នកបានឃើញវាទាំងអស់គ្នា។ នៅទីនោះក្រឡេកមើល ទៅក្រោយវិញ បានបង្ហាញការបើកសម្តែងថាពិតជាត្រឹមត្រូវណាស់។

256 ហេតុអ្វីពាក់សក់រុំ? ហេតុអ្វី ចៅក្រមអង់គ្លេសចាស់ ចៅក្រមជនជាតិ យូដា ធ្លាប់ពាក់សក់ ពួកគេ—ប្រើ—សក់ពាក់ធ្វើនៅប្រទេសអង់គ្លេស។ នៅពេលដែល គាត់...នោះជាអ្នកមានសិទ្ធិអំណាចខ្ពស់គាត់ពាក់សក់ពាក់។ ហើយនោះបាន បង្ហាញថាទ្រង់ឈរនៅទីនោះ ពាក់ស្លាបទេវតាទ្រង់ជាអាល់ហ្វា និងអូមេហ្គា។ ហើយទ្រង់ជាចៅក្រមជាន់ខ្ពស់ ហើយគ្មានអ្នកផ្សេងទៀតក្រៅ ពីទ្រង់ឡើយ។ ទ្រង់ទតមើលដូចជាអាល់ហ្វានិងអូមេហ្គា។ ហើយនៅទីនោះ ទ្រង់ជាបុរសវ័យក្មេង ម្នាក់ឬអាយុប្រម៉ានសាមសិបឆ្នាំជាង ពាក់សក់ពាក់ ពណ៌ស។ បង្ហាញថាទ្រង់ជា ព្រះដ៏ខ្ពស់បំផុត "ព្រះវរបិតាបានប្រគល់ការជំនុំជំរះ ដល់ព្រះហស្តនៃព្រះរាជបុត្រា ទាំងអស់។" ហាលេលូយ៉ា! ការបើកសម្តែងមិន ដែលខុសទេ! ចូរថ្លែងពីវា ទោះយ៉ាងណាក៏ដោយ មិនថាអ្វីដែលស្តាប់ មើលទៅហាក់ដូចជាទៅជាមួយ ព្រះបន្ទូល។

ហើយខ្ញុំចាំថាបួនឆ្នាំក្រោយ ប្រពន្ធរបស់ខ្ញុំ...

257 យើងដឹងថាយើងនឹងមានកូន។ អ្នករាល់គ្នានិយាយថា "នេះជាយ៉ូសែបដែល បានមក?

258 ខ្ញុំបាននិយាយថា "ខ្ញុំគិតថាហ្នឹងហើយ ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំនឹងមានយ៉ូសែប"

259 នៅពេលដែលវាបានកើតមកវាគឺជាសារ៉ា។ បន្ទាប់មក មានបុរសម្នាក់បាន ហៅខ្ញុំឡើងមក ហើយសើចដាក់មុខខ្ញុំ គាត់និយាយថា "និយាយថាតើអ្នកដឹងទេ? អ្នកចង់មានន័យថាឈ្មោះយ៉ូសែបមីន!" (បុរសនោះស្លាប់ហើយ។ បុរសនោះបាន ស្លាប់ហើយ។)

260 ខ្ញុំបាននិយាយថា "លោកម្ចាស់អើយ ខ្ញុំបាននិយាយថា 'ព្រះជាម្ចាស់ បាន ប្រាប់ខ្ញុំថាខ្ញុំ "នឹងមានកូនប្រុសមួយ" ហើយខ្ញុំនឹង 'ហៅឈ្មោះគាត់ថាយ៉ូសែប'"!"

261 មានមនុស្សបីនាក់ដែលបានចាកចេញពីព្រះវិហារនិកាយហើយមកឯ ក្រុមជំនុំរបស់យើង ហើយបានឮខ្ញុំនិយាយដូច្នេះ។ នៅពេលសារ៉ាកើតមក ពួកគេ បាននិយាយថា "ហ្ហា! គាត់ជាហោរាក្លែងក្លាយ។"

262 ខ្ញុំបាននិយាយថា "រង់ចាំមួយភ្លែត ស្ត្រីអើយ ខ្ញុំមិនដែលបាននិយាយថានៅពេលណាទេ ហើយព្រះក៏មិនបានប្រាប់ថានៅពេលណាដែរ។ ទ្រង់បានប្រាប់ខ្ញុំថា 'នឹងមាន...' ទ្រង់ក៏...ប្រាប់អ័ប្រាហាំថាពួកគេនឹង 'មានអ៊ីសាក' ប៉ុន្តែអ៊ីស្មាអែលបានកើតមករវាងពេលនោះ ប៉ុន្តែវាមិនបានយកវាចេញទេ។" ខ្ញុំបាននិយាយថា "ព្រះជាម្ចាស់ទ្រង់មានបន្ទូលថាខ្ញុំនឹងមានកូនប្រុស ហើយគាត់ត្រូវហៅឈ្មោះគាត់ថា 'យ៉ូសែប។'"

263 គ្រូពេទ្យបាននិយាយថា នៅពេលគាត់ឡើងមាន គាត់បាននិយាយថា "ខ្ញុំនឹងទៅចងបំពង់ទាំងនោះឥឡូវនេះ។" បាននិយាយថា "ខ្ញុំ..."

264 ខ្ញុំបាននិយាយថា "កុំធ្វើវាអី!" ខ្ញុំបាននិយាយថា...

265 គាត់បាននិយាយថា "មែនហើយ អ្នកអាចរៀបការម្តងទៀតហើយបង្កើតកូនប្រុសម្នាក់នោះ"

266 ខ្ញុំបាននិយាយថា "ខ្ញុំនឹងមានកូនដោយសារនាង! ព្រះមានបន្ទូលដូច្នេះ!" ខ្ញុំមិនអាចអានវាចេញពីព្រះគម្ពីរប៉ុន្តែវាត្រូវបានសរសេរនៅក្នុងចិត្តខ្ញុំ ដោយការបើកសម្តែងដោយជំនឿ ព្រះមានបន្ទូលដូច្នេះ! ខ្ញុំមិនចង់ងាកចេញពី សេចក្តីសន្យារបស់ព្រះតាមរយៈការមិនជឿទេ។

ពួកគេខ្លះនិយាយថា "អ្នកមានន័យថា យ៉ូសែបហ្វីន។"

ខ្ញុំបាននិយាយថា "ខ្ញុំចង់មានន័យថា 'យ៉ូសែប។'"

វេជ្ជបណ្ឌិតបាននិយាយថា "នាងមិនអាចមានកូនផ្សេងទៀតបានទេ។"

ខ្ញុំបាននិយាយថា "នាងនឹងមានកូនមួយទៀត។"

267 បួនឆ្នាំបានកន្លងផុតទៅ ជាចុងក្រោយនាងនឹងក៏ក្លាយជាម្តាយម្តងទៀត។

268 បន្ទាប់មកស្ត្រីម្នាក់ (ជាហោរាក្លែងក្លាយមួយត្រូវបានបញ្ជូនទៅពាសពេញប្រទេស)សរសេរពាក្យខ្លះ បាននិយាយថា "មេឌានឹងស្លាប់ក្នុងកំឡុងពេលនេះពីព្រោះខ្ញុំត្រូវបានគេបញ្ជូនឲ្យដឹកនាំប៊ីលលី។" ហើយវាបាននិយាយបន្តថា "គាត់នឹងមិនស្តាប់ខ្ញុំទេ ព្រោះខ្ញុំជាស្ត្រី ហើយព្រះនឹងធ្វើការនោះជាមួយគាត់ ឥឡូវនេះដោយសម្លាប់ប្រពន្ធរបស់គាត់។"

269 ខ្ញុំបាននិយាយថា "ព្រះជាម្ចាស់ទ្រង់បានបញ្ជូនព្រះយេស៊ូវគ្រីស្ទមកដឹកនាំខ្ញុំ" ឃើញទេ? ហើយខ្ញុំបាននិយាយថា "ខ្ញុំដឹកនាំដោយព្រះវិញ្ញាណ។

270 មេដាដ៏គួរឱ្យអាណិត។ យើងមានគិលានុបដ្ឋាយិកាម្នាក់ដែលត្រូវបានព្យាបាលនៅទីនោះ អ្នកទាំងអស់គ្នាដឹងហើយគឺលោកស្រីម៉ូគេន (និងគិលានុបដ្ឋាយិកាម្នាក់របស់ មេយូសជាករណីកាន់តែអាក្រក់។) មែនហើយសម្លេងនាងនៅក្នុងខ្សែរអាត់ "ស្លាប់" ប្រហែលម្ភៃឆ្នាំពីជម្ងឺមហារីក "មហារីក" នៅល្វីលវីល នៅខាងស្ដាំលើកំណាត់ត្រាមន្ទីរពេទ្យបាបទីស្ទ។ នាងកំពុងសំរាកព្យាបាលនៅ—ជេហ្វីសាន់វីលក្នុងមន្ទីរពេទ្យឥឡូវនេះ។ នាងបាននៅទីនោះអស់រយៈពេលជា ច្រើនឆ្នាំមកហើយ ពីព្រោះព្រះមានបន្ទូលថា "នាងនឹងរស់"

271 ហើយ ដូច្នេះ មេដាស្រឡាញ់នាង ហើយនាងបាននិយាយថា "ខ្ញុំចង់ឲ្យម៉ាគីមកជាមួយខ្ញុំ ប៊ីលលី ខ្ញុំមិនមានអារម្មណ៍ចង់ទៅមន្ទីរពេទ្យទេ។"

272 ខ្ញុំបាននិយាយថា "កុំធ្វើ...យើងស្រឡាញ់ម៉ាហ្គី ប៉ុន្តែម៉ាហ្គីមិនមែនជាព្រះរបស់យើងទេ គេជាបងស្រីរបស់យើង" ហើយខ្ញុំបានឡើងទៅរោងម៉ាស៊ីនកិនស្រូវហ្គ្រីន។ នាងបានទទួលខ្ញុំ។ ពីព្រោះខ្ញុំស្រឡាញ់នាង។ ខ្ញុំបានឡើងទៅរោងម៉ាស៊ីនកិនស្រូវហ្គ្រីន។

273 ហើយនាងបាននិយាយថា "ប៊ីលលីតើអ្នកគិតថាខ្ញុំនឹងត្រូវស្លាប់ឬទេ?"

274 ហើយខ្ញុំបាននិយាយថា "ខ្ញុំមិនដឹងទេ ប៉ុន្តែទារកនឹងកើតមកទោះយ៉ាងណាក៏ដោយ។ អ្នកនឹងមានយ៉ូសែបមួយ។

275 នាងនិយាយថា "តើគាត់នេះឬ?"

276 ខ្ញុំបាននិយាយថា "ខ្ញុំមិនដឹងទេ អូនសម្លាញ់។ ខ្ញុំមិនអាចនិយាយបានទេ ប៉ុន្តែព្រះមានបន្ទូលថាគាត់នឹងមានយ៉ូសែប ហើយយើងនឹងមានយ៉ូសែប។ ខ្ញុំមិន ខ្វល់ពីអ្វីៗដែលគេនិយាយនោះទេ យើងនឹងមានយ៉ូសែប។ ដ្បិត ជាព្រះ តែមួយ ដែលបានប្រាប់ខ្ញុំពីរការបើកសម្ដែងទាំងអស់ ទ្រង់ប្រាប់ខ្ញុំ*អញ្ចឹង* ទ្រង់មិន ដែល បរាជ័យលើអ្វីឡើយហើយទ្រង់នឹងមិនបរាជ័យឡើយ។"

277 ខ្ញុំបានឡើងទៅរោងម៉ាស៊ីនដើម្បីអធិស្ឋាន។ ហើយខ្ញុំបានចាប់ផ្ដើមនៅទីនោះ។ មានពន្លឺបានឈរនៅទីនោះ ពន្លឺព្យួរនៅចន្លោះដើមឈើពីរ បាននិយាយថា "ចូរត្រឡប់ទៅវិញ គឺរកសៀវភៅ" ខ្ញុំបានត្រលប់ទៅរក ព្រះគម្ពីរវិញ ហើយនៅពេលនោះខ្ញុំកំពុងដេកក្នុងឡានរបស់ខ្ញុំ នៅពេលវាកើតឡើង ខ្យល់បានបក់ទៅកន្លែងដែលណាថាន់អង្គុយនិយាយ ទៅដាវីឌ និយាយថា៖ "ចូរទៅប្រាប់

ដាវីឌជាអ្នកបម្រើរបស់យើង ខ្ញុំយកគាត់ពីហ្វូងចៀមនោះ ពីអ្នកផ្តល់ចំណីដល់ចៀមពីរបីក្បាលរបស់ឪពុកវា ហើយខ្ញុំបានធ្វើឱ្យគាត់មានកេរ្តិ៍ឈ្មោះដូចជាបុរសអស្ចារ្យ។" (មិនមែនទាំងអស់ទេ—គឺឈ្មោះអស្ចារ្យបំផុត) ប៉ុន្តែគ្រាន់តែ*ដូចជា*បុរសអស្ចារ្យ។ មិនដែលធ្វើឱ្យគាត់ដូចប៊ីលីក្រាហាំ ប៉ុន្តែ...ដាក់ឈ្មោះឱ្យគាត់ថា អ្នកដឹងទេ) បាននិយាយថា "ខ្ញុំបានធ្វើវា ប៉ុន្តែ" បាននិយាយថា "ខ្ញុំមិនអាចអនុញ្ញាតឱ្យគាត់សាងសង់ព្រះវិហារបានទេ ប៉ុន្តែកូនប្រុសរបស់គាត់..."

278 ហើយដូចដែលបាននិយាយចប់ហើយថា "កូនប្រុសរបស់គាត់" អូខ្ញុំអើយ គឺវានៅទីនោះ។

279 ខ្ញុំបាននិយាយថា "យ៉ូសែប?" ត្រឹមត្រូវហើយ។

280 នៅខាងក្រោមផ្ទះដែលខ្ញុំបានទៅ។ ហើយនៅទីនោះ ក្មេងតូចហើយថ្លោសណាស់នាង—...(ក្មេងប្រុសតូច) នាងមិនអាចដើរនៅទីវាលបានទេ។ ខ្ញុំរត់បោះដៃឱបនាងហើយនិយាយថា "អូន! យ៉ូសែបកំពុងមកហើយ។ យ៉ូសែបកំពុងនៅតាមផ្លូវរបស់គាត់។"

281 អ្នកណាម្នាក់ដឹងហើយដោយការវះកាត់ អ្នកមិនអាចអោយទារកធ្លាក់បានទេ។ នោះយប់នោះទារកបានកើតមក បែកទឹកភ្លោះ និងអ្វីៗផ្សេងទៀត។

282 ព្រឹកបន្ទាប់នៅម៉ោង៧ព្រឹក យើងបានទៅដល់មន្ទីរពេទ្យ វេជ្ជបណ្ឌិតបាននិយាយថា "អូ! សេចក្តីមេត្តាករុណា សេចក្តីល្អ"

283 ខ្ញុំបានថើបលានាងហើយនិយាយថា "អូនសម្លាញ់ វាមិនយូរទេយ៉ូសែប នឹងបាននៅទីនេះ។ នាងបោះជំហានទៅ នៅលើតុប្រតិបត្តិការវះកាត់។

284 ពីរបីនាទីក្រោយ គិលានុប្បដ្ឋាយិកាបានចុះមកនិយាយថា "អ្នកជាបងប្រុសប្រាណហាំមែនឬ?"

285 ខ្ញុំបាននិយាយថា "មែនហើយ"

286 នាងបាននិយាយថា "អ្នកទទួលបានក្មេងប្រុសស្រស់ស្អាតទំងន់៧ ផោន៣អោន"

287 ខ្ញុំបាននិយាយថា "យ៉ូសែបកូនប្រុសប៉ា សូមស្វាគមន៍" បាទ! ហេតុអ្វី? ហេតុអ្វី? តើវាគឺជាអ្វី? វាមិនត្រូវបានសរសេរនៅក្នុងព្រះគម្ពីរថានឹងកើតឡើងនោះទេប៉ុន្តែគឺជាព្រះតែមួយ ព្រះគម្ពីរដែលបានបង្ហាញវាដល់អ័ប្រាហាំ យើង

មិនបានគិតពីការស្លាប់នៃស្បូនរបស់នាងទេ វាមិនអាចទៅរួចតាមវិធីនោះ។ អ្នកមិនរង្គោះរង្គើចំពោះការសន្យារបស់ព្រះតាមរយៈការមិនជឿទេ ប៉ុន្តែអ្នកផ្តល់ ការសរសើរដល់ព្រះថាវាត្រូវតែកើតឡើង! ខ្ញុំមិនខ្វល់ពីអ្វីដែលវេជ្ជបណ្ឌិត និយាយអ្វីៗផ្សេងទៀតទេនឹងមកតាមគ្រប់មធ្យោបាយ ប៉ុន្តែកុំជឿវា ជាជាការភូតកុហករបស់អារក្ស។ បាទលោកពិត។ សេចក្តីជំនឿកើតឡើង រួមជាមួយការប្រព្រឹត្តដើម្បីបង្កើតការសន្យា។ (សូមប្រញាប់។)

288 គ្រាន់តែដូចអ្វីដែលវាបាននិយាយថា "វ៉ាហាបជាស្រីសំផឹង" បានរាប់ជាសុចរិតដោយសារការប្រព្រឹត្ត។ តែហេតុអ្វី? គឺជំនឿរបស់នាង!

289 នាងបាននិយាយថា "ខ្ញុំបានឮថាព្រះជាម្ចាស់គង់នៅជាមួយអ្នក" នាងមិនចង់ឃើញទេរបៀបដែលយ៉ូស្វេពាក់សក់របស់គាត់ឬរបៀបដែលគាត់ស្លៀកសម្លៀកបំពាក់របស់គាត់។ នាងបាននិយាយថា "ខ្ញុំយល់ថាព្រះនៅជាមួយអ្នក" អ្វីដែលសំខាន់ នាងត្រៀមខ្លួនរួចរាល់។

290 ដូចគ្នានឹងនិមិត្តពិតនាពេលបច្ចុប្បន្ននេះ (ខ្ញុំនឹងបញ្ចប់បន្តិចទៀតនេះ) និមិត្តពិតពីព្រះថ្ងៃនេះវាជាព្រះបន្ទូលសន្យាសម្រាប់ថ្ងៃនេះ។ និយាយថា "និមិត្តទាំងនេះបងប្រុសប្រាណហាំ តើអ្នកយកវាពីណាមក?" មនុស្សជំពប់ដួលនៅទីនោះ។ តើកិច្ចការ២:១៧បាននិយាយថាម៉េច "វានឹងកើតឡើងនៅថ្ងៃចុងក្រោយដែលមនុស្សនឹងឃើញការនិមិត្ត មនុស្សចាស់នឹងយល់សប្តិឃើញការជាក់ស្តែង។" ត្រូវឬមិនត្រូវ? នោះជាអ្វីដែលព្រះគម្ពីរបានចែង។

291 មែនហើយឥឡូវនេះបើដូច្នោះមែនឃើញទេម៉ាឡាគីជំពូកទី៤និងស្វែង យល់ថាតើវាមិនត្រូវបានសន្យានៅថ្ងៃនេះទេឬ។ តើអ្នកអាចមានជំនឿលើវាដោយ របៀបណា? នេះព្រះគម្ពីរបាននិយាយយ៉ាង ដូច្នេះ!

292 ឥឡូវនេះអ្នកមើលក្នុងលូកា១៧:៣០ហើយអានវា។ ព្រះយេស៊ូវមានបន្ទូលថា "ដូចជានៅក្នុងថ្ងៃនៃក្រុងសូដុមនឹងមកដល់ នៅពេលដែលកូនមនុស្សមក។ គឺដូចជានៅក្រុងសូដុំមដែរ។ ឥឡូវនេះ សូមក្រឡេកមើលទីតាំងរបស់ លោកិយថ្ងៃនេះក្រុងសូដុម។ សូមក្រឡេកមើលលោកប៊ីលលីក្រាហាំនិង អូរ៉ាលរ៉ូប៊ឺត សាក្សីពីរនាក់នៅទីនោះធ្វើបន្ទាល់ដល់វិហារនិកាយ។ មួយទៅមេតូឌីស បាទីស្ទនិង ព្រីសប៊ីធីរៀន មួយទៀតទៅពេនទីកុស្ត។ *មួយនេះ*ហើយ*មួយនោះ*។

293 ប៉ុន្តែចាំថា អ័ប្រាហាំមិនបាននៅក្រុងសូដុំមទេ គាត់ត្រូវបានហៅចេញរួចហើយ។ ហើយមានម្នាក់បានស្នាក់នៅហើយនិយាយជាមួយគាត់! ហើយម្នាក់ដែលបានស្នាក់នៅហើយនិយាយជាមួយគាត់ ព្រមទាំងបានបង្ហាញសញ្ញាដល់គាត់។ ពីក្រោយខ្នងរបស់ទ្រង់ ទ្រង់មានបន្ទូលថាសារ៉ានឹងមានកូន ជាកូនដែលគាត់បានរង់ចាំ។ អាម៉ែន។ ងាកបែរខ្នង។ ហើយគាត់បានហៅទ្រង់ថា "ព្រះអេឡូហ៊ីម"

294 ឥឡូវនេះ ការនេះកើតឡើងនៅថ្ងៃនេះ ពីព្រោះយើងមានសេចក្ដីជំនឿ។ ហើយខ្ញុំដឹងនេះគឺជាព្រះ គឺដោយសារតែបទគម្ពីរផ្សេងទៀតចង្អុលទៅសម័យកាល នេះ។ វិវរណៈ១០ បាននិយាយថា "នៅសម័យកាលនៃសាររបស់ទេវតាទី៧ នៅពេលដែលគាត់ចាប់ផ្ដើមបន្លឺសម្លេងសាររបស់គាត់" មិនមែននៅក្នុងកម្មវិធី ប្រោសឲ្យជាទេ ប៉ុន្តែសារដែលតាមកម្មវិធីប្រោសឲ្យជា។

295 ព្រះយេស៊ូវបានចេញទៅហើយផ្សព្វផ្សាយ។ ទ្រង់មានបន្ទូលថា "គាត់បានព្យាបាលមនុស្សឈឺហើយធ្វើអ្វីគ្រប់យ៉ាង។ អូ គ្រូវ័យក្មេងនោះ ដែលជាហោរា គាត់គឺជាសមាជិកដ៏អស្ចារ្យ។ យើងចង់បានទ្រង់មកនៅក្នុងពួកជំនុំរបស់យើង"

296 ប៉ុន្តែនៅថ្ងៃមួយទ្រង់បានក្រោកឈរឡើង ហើយមានបន្ទូលថា "ខ្ញុំនិងបិតារបស់ខ្ញុំគឺតែមួយ" អូខ្ញុំអើយ។ ពួកគេមិនចង់បានទ្រង់ទៀតទេ។ មែនហើយ។ អូ!

297 "លើកលែងតែអ្នកបរិភោគសាច់របស់កូនមនុស្សហើយផឹកព្រះឈាមរបស់ទ្រង់!" ទ្រង់មិនបានពន្យល់ទេ។ បានចែងថា "លើកលែងតែអ្នកបរិភោគសាច់របស់កូនមនុស្សហើយផឹកឈាមរបស់ទ្រង់មិនដូច្នេះទេអ្នកគ្មានជីវិតនៅក្នុងខ្លួនអ្នកទេ។"

298 ហេតុអ្វី ខ្ញុំស្រមៃថា គ្រូពេទ្យនិងគិលានុប្បដ្ឋាយិកាមួយចំនួនបាននិយាយថា "មិត្តតូចនេះជាបិសាច គាត់ព្យាយាមឱ្យយើងផឹកឈាមរបស់គាត់។" ឃើញទេ ពួកគេមិនបានយល់ទេ។ គាត់បានជ្រាបហើយ។

299 ប៉ុន្តែពួកគេដែលជាសិស្ស ពួកគេប្រហែលជាមិនអាចពន្យល់ពីវាបានទេ ប៉ុន្តែពួកគេបានកំណត់នៅទីនោះហើយជឿថាវាទោះជាយ៉ាងណាក៏ដោយ អាម៉ែន ដ្បិតវាត្រូវបានបង្ហាញឱ្យពួកគេដឹង។ បាទមែនហើយ។ ពួកគេបានស្គាល់វា ព្រះគម្ពីរបានប្រកាសអំពីវា។

300 វាអាចសួរខ្ញុំអំពីរឿងនេះ បើអ្នកអាចនិយាយថា "ហេតុអ្វីបានជាអ្នកមានជំនឿជឿជាក់លើនិមិត្តទាំងនេះ នៅពេលដែលមានរឿងមិនពិតជាច្រើនក្លែងបន្លំ?

301 ខ្ញុំនឹងនិយាយរឿងតូចមួយ ដែលខ្លាំង មួយភ្លែតឥឡូវនេះ។ នៅពេលដែលអ្នកក្លែងបន្លំជាច្រើននៅជុំវិញ សូមចាំបងប្អូនអើយ ពួកគេក៏និយាយផងដែរថាពួកគេគួរតែនៅទីនេះជាមួយគ្នា។ ពិតហើយ ដូចគ្នានឹងគ្រារបស់លោកម៉ូសេដែរ។ លោកម៉ូសេបានចុះដើម្បីអនុវត្តកិច្ចការរបស់ព្រះនៅចំពោះមុខមនុស្ស ហើយមានយ៉ាមប្រេសនិងយ៉ាណេសឈរនៅទីនោះ។ ប៉ុន្តែតើនរណាជាអ្នកដំបូងដែលធ្វើវា? បន្ទាប់មក មានអ្នកផ្សេងទៀតទាំងនេះដែលជាអ្នកក្លែងបន្លំ ពីព្រោះវាត្រូវតែមាន របស់ពិតសម្រាប់ពួកគេក្លែងបន្លំ។ បើពួកគេជាវត្ថុដើម...អាហ្វា។ អត់ទេ បើអញ្ចឹងនោះយើងមិន—មិនបាត់បង់ទេ។ យើងដឹងពីកន្លែងដែលយើងនៅ ឃើញទេ ឃើញទេ ដោយបទគម្ពីរនិងតាមរយៈការបើកសម្តែងរបស់ព្រះជាម្ចាស់។ នោះហើយជាមូលហេតុដែលអ្នកនៅតែឈរមាំ។

302 "ហេតុអ្វី*បុរសនេះ* គាត់មើលឃើញការជាក់ស្តែងជាដើម។ គាត់ធ្វើ*បែបនេះ* ហើយគាត់រត់ជុំវិញជាមួយប្រពន្ធគាត់។ គាត់ជឿលើព្រះទាំងបីនិងអ្វីៗទាំងអស់នេះ។" វាមិនគួរឱ្យងឿងឆ្ងល់ទេ។ ហើយនេះជារឿងមួយដែលពួកគេមិនអាចក្លែងធ្វើបានគឺៈ ព្រះបន្ទូលទេ! សូមកត់សម្គាល់។ ពួកគេអាចមានរបស់ទាំងអស់នេះ ពួកគេអាចនិយាយភាសាដទៃ ពួកគេអាចស្រែកច្រៀង រាំនៅក្នុងព្រះវិញ្ញាណ បានដេញអារក្ស។ អ៊ូ—ហ៊ូ។ ត្រឹមត្រូវហើយ។ ត្រឹមត្រូវហើយ។ ប៉ុន្តែព្រះបន្ទូលបានថ្លឹងថ្លែងពួកគេ។ ឃើញទេ? ពិតជាត្រឹមត្រូវ។ នេះជាកន្លែងដែលវាមកដល់។ ដូចលោកម៉ូសេនិងយ៉ាមប្រេស...

ហើយចងចាំថាទ្រង់មានបន្ទូលថា "ដូចជាយ៉ាមប្រេសនិងយ៉ាណេសបានប្រឆាំងនឹងម៉ូសេ នៅថ្ងៃចុងក្រោយនឹងមានអ្នកក្លែងបន្លំទាំងនេះ រស់ឡើងវិញ នៅលើផែនដីម្តងទៀត" តើទ្រង់មានបន្ទូលអញ្ចឹងមែនអត់? [ក្រុមជំនុំនិយាយថា អាម៉ែន] មែនហើយ យើងនឹងមានពួកគេ។

303 ប៉ុន្តែការនោះមិនបានធ្វើឲ្យលោកម៉ូសេរង្គើឡើយ។ នៅពេលដែលលោកម៉ូសេបានងាកហើយបានធ្វើការអស្ចារ្យនៅក្នុងព្រះនាមព្រះអម្ចាស់ ហើយអ្នកក្លែងបន្លំឈរនៅទីនេះធ្វើអ្វីៗដូចគ្នា។ នោះក៏មិនអាចបញ្ឈប់គាត់បានឡើយ ក្រែងថា "មែនហើយ ខ្ញុំគិតថាខ្ញុំគួរតែឈប់ប្រសើរជាង ហើយចេញទៅវាលរហោស្ថាន

វិញ។″ គាត់ស្នាក់នៅទីនោះ។ ដើម្បីអ្វី? វាត្រូវបានគេបង្ហាញឱ្យគាត់ដឹង។ ហាលេលូយ៉ា! គាត់បានស្គាល់ដោយព្រះបន្ទូលនៃព្រះ។ គាត់បានដឹងថានៅ ទីបំផុតព្រះបន្ទូលនឹងតាមទាន់ពួកគេ។ គាត់បានដឹងថានឹងមានពេលដែល ព្រះបន្ទូលនឹងបង្ហាញខ្លួនវា ហើយពួកគេមិនអាចទៅណាបានទេ។

304 ដូច្នេះខ្ញុំបានដឹងអំពីរឿងនេះ ប៉ុន្មានឆ្នាំកន្លងមកនេះ ឃើញទេ ថាត្រឹមត្រូវនៅពេលនោះនឹងមក។ នៅពេលដែលការអស្ចារ្យណាមួយដែលព្រះចាត់មកជាការអស្ចារ្យដ៏ពិតប្រាកដ តែងតែជាការផ្លាស់ប្តូរនៅក្នុងប្រព័ន្ធទាំងមូល។ បើព្រះជាម្ចាស់ចាត់អ្វីមួយចូលទៅក្នុងក្រុមជំនុំ ហើយប្រព័ន្ធចាស់មិនត្រូវបានផ្លាស់ប្តូរទេ ទ្រង់បានបញ្ជូនវាមកដោយឥតប្រយោជន៍ទេ។ ពេលរាជ្យសារចេញទៅ ជាមួយទីសំគាល់និងការអស្ចារ្យ នោះហើយជារាជ្យសារពិត ចូរធ្វើតាមចុះ។ នៅពេលដែលព្រះយេស៊ូវបានចេញទៅព្យាបាលអ្នកជំងឺ បន្ទាប់មកបានផ្សាយ រាជ្យសាររបស់ទ្រង់ ‶ខ្ញុំនិងព្រះបិតារបស់ខ្ញុំគឺតែមួយ ខ្ញុំជាទ្រង់។″ ឃើញទេ? ឃើញទេ ពួកគេ—ពួកគេមិនជឿទេ។ ពួកគេជឿការអស្ចារ្យរបស់ទ្រង់។ ទ្រង់មានបន្ទូលថា ‶បើអ្នកមិនអាចជឿខ្ញុំទេ ចូរជឿការអស្ចារ្យទាំងនោះ ដ្បិតពួកគេធ្វើបន្ទាល់ប្រាប់អ្នកថាខ្ញុំជានរណា។″ អូខ្ញុំអើយ។ ថ្វាយសិរីល្អ! នរណាជាអ្នកដំបូង? លោកម៉ូសេ! បន្ទាប់មកមានពួកគេជាអ្នកក្លែងបន្លំ។ ប៉ុន្តែការពិតដ៏អស្ចារ្យនៅតែមានដដែលរវាងអ្វីដែលត្រូវនិងអ្វីដែលខុស ពួកគេមិនអាចទទួលរាជ្យសារបានទេ! ពួកគេមិនអាចទទួលយករាជ្យសារ ដែលមិនផិតក្បត់ ដែលមកពីព្រះបន្ទូលរបស់ព្រះបានទេ។

305 ខ្ញុំមិនខ្វល់ទេ យូដាសអាចធ្វើទីសំគាល់និងការអស្ចារ្យគ្រប់យ៉ាង។ ប៉ុន្តែនៅពេលដែលគាត់បានមកទទួលព្រះវិញ្ញាណបរិសុទ្ធនៅថ្ងៃបុណ្យទី៥០ គាត់បានបង្ហាញពណ៌របស់គាត់។ នោះជាអារក្សអាចមកហើយក្លែងធ្វើជាត្រឹមត្រូវរហូតដល់វាមកដល់ព្រះបន្ទូលនេះ ប៉ុន្តែវាមិនអាចទទួលយកព្រះបន្ទូលទាំងអស់បានទេ។ វាអាចនាំយកទាំងអស់ប្រហែលជាដល់ពាក្យមួយដូចជាអេវ៉ាបានធ្វើ ដូចអារក្សបានធ្វើចំពោះអេវ៉ា ប៉ុន្តែវាមិនអាចឆ្លងកាត់ទាំងអស់បានទេ។ ដោយសារតែ...រឿងមួយគត់គឺជារូបកាយទាំងមូលរបស់ព្រះគ្រីស្ទ។ ឃើញទេ ព្រះបន្ទូលឥឡូវនេះ។ ក៏មិនអាច...ពួកគេមិនអាចទទួលយករាជ្យសារឥឡូវនេះ ហើយក៏មិនអាចដូចចាមប្រេសនិងយ៉ាណេសដែលយកសាររបស់លោកម៉ូសេ។ ពួកគេមិនអាចធ្វើបានទេ។ ការប្រព្រឹត្តរបស់ពួកគេពីការក្លែងបន្លំត្រូវបានបង្ហាញ ឱ្យ

គេស្គាល់ ពីព្រោះពួកគេមិនអាចធ្វើបានតាមព្រះបន្ទូលរបស់ព្រះ ដែលបាន បង្ហាញ អោយឃើញថាត្រឹមត្រូវដោយសារពួកហោរាដែលបានចាក់ប្រេងតាំង ឃើញទេ?

306 ពួកគេមិនអាចដើរតាមអ៊ីស្រាអែលបានទេ។ ហេតុអ្វី? ពួកគេជានិកាយ ជាទារកអេហ្ស៊ីប! ពួកគេមិនអាចដើរតាមព្រះបន្ទូលនោះបានទេ។ បើពួកគេធ្វើតាម ពួកគេត្រូវតែចាកចេញពីស្រុកអេស៊ីប។ ទន្លេរនីល អ្វីទាំងអស់ គឺល្អសម្រាប់ពួកគេ ហើយពួកគេមិនអាចធ្វើតាមបានទេ។ ទោះបីពួកគេអាចក្លែងធ្វើអ្វីដែលលោកម៉ូសេបានធ្វើក៏ដោយ ប៉ុន្តែភាពល្ងីល្ងើរបស់ពួកគេត្រូវបានបង្ហាញឱ្យឃើញ នៅពេលវេលាមកដល់។ បន្ទាប់មក ព្រះជាម្ចាស់ពិតជាបានចាក់បង្ហូរវាមកលើពួកគេ។

307 ដូចគ្នាឥឡូវនេះ! ពួកគេអាចធ្វើការក្លែងបន្លំរឿងគ្រប់យ៉ាង ដែលគ្មានប្រយោជន៍ ក្រៅពីបំផ្លាញអ្វីដែលត្រូវ ហើយកូនដែលជឿគឺដឹងថាជាការពិត។ អ៊ូ—ហ៊ូ។ នៅទីនេះអ្នកឃើញច្បាស់ បន្ទាប់មក ការងារនៃភាពល្ងីល្ងើនៃការក្លែងបន្លំរបស់ពួកគេ។ បើកិច្ចការរបស់អ្នក—បើកិច្ចការរបស់អ្នកគឺជាព្រះបន្ទូលដ៏ពិតហើយបានបើកសម្តែងភាពត្រឹមត្រូវ ដោយជំនឿរបស់អ្នក វានឹងបង្ហាញ ហើយដូចជាការសន្យារបស់ព្រះ នៅក្នុងព្រះបន្ទូលដើមដែលបានសរសេរ។

308 ព្រះយេស៊ូវទ្រង់មានបន្ទូលថា "បើខ្ញុំមិនធ្វើការ..." ចូរស្តាប់ដោយយកចិត្តទុក ដាក់ចុះ! "បើខ្ញុំមិនធ្វើ..."សូមឱ្យខ្ញុំបន្ថែមពាក្យនេះទៅក្នុងវា។ "នោះគឺបើខ្ញុំមិនធ្វើការដែលបទគម្ពីរប្រាប់អ្នកថាខ្ញុំនឹងធ្វើដូច្នេះ...នៅអាយុខ្ញុំ នៅពេលខ្ញុំមក ជាអ្វីដែលព្រះមេស្ស៊ីបានសន្យាថានឹងធ្វើនៅពេលដែលទ្រង់ យាងមក។ បើអ្វីដែលខ្ញុំធ្វើ បើព្រះជាម្ចាស់មិនបង្ហាញថាព្រះបន្ទូលដែលទ្រង់បាន មានបន្ទូលថានឹងកើតឡើងទេ បើជីវិតរបស់ខ្ញុំមិនធ្វើអោយព្រះបន្ទូលនោះរស់នៅ ដូចអ្វីដែលបានចែងថានឹងកើតឡើង..." កុំខកខានចំណុចនេះឲ្យសោះ! ព្រះយេស៊ូវមានបន្ទូលថា "អ្នកដឹងពីអ្វីដែលព្រះមេស្ស៊ីបានសន្យាថាត្រូវធ្វើ។ បន្ទាប់មក បើព្រះបន្ទូលដែលបានចែងនោះ វាមិនបើកសម្តែងតាមរយៈខ្ញុំទេ នោះខ្ញុំមិនមែនជាទ្រង់ទេ។" អាម៉ែន! "បន្ទាប់មក សម័យកាលដែលខ្ញុំនិយាយ គឺខុស អ្វីដែលយ៉ូហានបាននិយាយអំពីខ្ញុំគឺមិនពិតទេ។ ហើយបើខ្ញុំមិនមែនជាព្រះ មេស្ស៊ីនោះទេ បើកិច្ចការដែលព្រះមេស្ស៊ីសន្យាថាធ្វើទ្រង់—ទ្រង់ត្រូវតែធ្វើ 'ព្រះអម្ចាស់ជាព្រះរបស់អ្នកនឹងលើកពួកហោរាម្នាក់ដូចខ្ញុំដែរ' ហើយមើល អ្នកមិនមានហោរារាប់រយឆ្នាំហើយ បើពួកគេធ្វើការដែលខ្ញុំបានធ្វើដែលព្រះបានសន្យា បើពួកគេមិនបានបង្ហាញនៅក្នុង

ជីវិតបច្ចុប្បន្នរបស់ខ្ញុំ បន្ទាប់មកខ្ញុំមិនមែន ទ្រង់ទេ។ តែបើព្រះបន្ទូលបានសន្យា នៃយុគសម័យនេះ ត្រូវបានបើកសម្ដែងនៅ ក្នុងខ្ញុំ បន្ទាប់មកខ្ញុំគឺជាទ្រង់ហើយ ការសន្យាគឺមក រកអ្នក។” អូខ្ញុំអើយ មិនបានឃើញថាតើវាអាចមានចំនួនប៉ុន្មាន! “បើការសន្យាមិន...” អូ!

309 “បើសិនជាសេចក្ដីសន្យានៅថ្ងៃនោះត្រូវបានសម្ដែងនៅក្នុងពន្ធកិច្ចរបស់ខ្ញុំ” ព្រះយេស៊ូវមានបន្ទូលថា “ខ្ញុំគឺជាទ្រង់។ ដូច្នេះបើអ្នកពិបាកជឿថាខ្ញុំជានរណា នោះចូរមើលការប្រព្រឹត្តដែលបានសន្យាសម្រាប់ថ្ងៃនេះចុះ។” អាម៉ែន! “មើលទៅ កាន់ការប្រព្រឹត្តដែលបានសន្យា។ បើការណាមួយមិនត្រូវបានបំពេញ នៅក្នុងខ្ញុំទេ នោះសូមកុំជឿខ្ញុំ ព្រោះខ្ញុំបានប្រាប់អ្នកខុស។ អ្នកមិនអាចជឿខ្ញុំបានទេ គ្រាន់តែ មើលទៅអ្វីដែលព្រះគម្ពីរបានចែងថានឹងកើតឡើងនៅសព្វថ្ងៃនេះ។ បើវាមិនកើត ឡើងទេ នោះវាមិនត្រឹមត្រូវទេ។ បើរឿងមិនពិតទាំងនេះមិននៅទីនេះ នោះរឿង ទាំងអស់នេះនិងអ្វីដែលត្រូវបានរំពឹងថានឹងកើតឡើង។ បើវាមិននៅទីនេះ ទេនោះ គឺខ្ញុំខុស។ ប៉ុន្តែបើកើតដូច្នោះមែន” ព្រះយេស៊ូវមានបន្ទូលថា “នោះខ្ញុំគឺជាទ្រង់ ហើយ។” អាម៉ែន! “ខ្ញុំគឺជាទ្រង់ដែលត្រូវបានសន្យាថានឹងមក”

អូ ខ្ញុំអើយ កិច្ចការដដែលដែលត្រូវបានសន្យានៅក្នុងសម័យកាលរបស់ទ្រង់ បានបង្ហាញការពិតថាទ្រង់គឺជាព្រះមេស៊ី។ តើអ្នកមិនជឿទេឬ? [ក្រុមជំនុំនិយាយ ថាអាម៉ែន—Ed]

310 មែនហើយ ឥឡូវនេះបងប្អូនអើយ បើការប្រព្រឹត្តរបស់លូកាជំពូក១៧ និង គម្ពីរខ៣០ គឺជាការសន្យារបស់ព្រះយេស៊ូវគ្រីស្ទ មុនពេលការយាងមក ម្ដងទៀត លោកិយនេះនឹងត្រលប់ដូចជាក្រុងសូដុំម ហើយអ្នកនាំសារនឹងចេញទៅ ហើយអ្វី ៗនឹងត្រូវបានធ្វើយ៉ាងពិតប្រាកដ។ បើវាមិនកើតឡើងទេ នោះសុំកុំជឿខ្ញុំ ថាខ្ញុំបាន ប្រាប់អ្នកពីសេចក្ដីពិត។ ប៉ុន្តែបើវាកំពុងកើតឡើង នោះចូរជឿថាវាគឺ ជាទ្រង់ “នៅ ថ្ងៃនោះកូនមនុស្សនឹងលេចមក” អាម៉ែន! កូនមនុស្សនឹងលេចមក ក្នុងរូបកាយ ជាសាច់ឈាម អ្នកទាំងអស់គ្នាដែលជាក្រុមជំនុំ គឺដូចកាលពីមុន នៅថ្ងៃនៃក្រុង សូដុមដែលជាក្រុមមួយដែលឃ្លាតឆ្ងាយពីពួកគេទាំងអស់ ដោយបានជឿសេចក្ដី សន្យានៃព្រះ។ សូមថ្វាយសិរីល្អ!

311 បន្ទាប់មក កិច្ចការដែលព្រះវិញ្ញាណបរិសុទ្ធកំពុងតែធ្វើនៅសព្វថ្ងៃនេះ តាមរយៈនិមិត្តមិនដែលបរាជ័យ ការសន្យាមិនដែលបរាជ័យ រាល់ទីសំគាល់របស់

ពួកសាវកដែលបានសន្យាព្រះគម្ពីរ នៃគម្ពីរម៉ាឡាគី៤ ហើយ អូ វិវរណៈ១០:៧ ទាំងអស់កំពុងតែត្រូវបានកើតឡើង បានបំពេញ ហើយត្រូវបានបង្ហាញដោយ វិទ្យាសាស្ត្រគ្រប់វិធីទាំងអស់។ ហើយបើខ្ញុំមិនបានប្រាប់អ្នកពីការពិតទេ នោះរឿង ទាំងនេះនឹងមិនកើតឡើងទេ។ ប៉ុន្តែបើខ្ញុំបានប្រាប់អ្នកពីសេចក្តីពិត នោះវានឹង បញ្ជាក់ថាខ្ញុំបានប្រាប់អ្នកពីសេចក្តីពិត។ ទ្រង់នៅតែដូចគ្នាកាលពីម្សិល មិញ ថ្ងៃនេះនិងជារៀងរហូត ហើយការលេចចេញពីព្រះវិញ្ញាណរបស់ទ្រង់ កំពុងចាប់ កូនក្រមុំ។ សូមឱ្យសេចក្តីជំនឿ និងការបើកសម្តែងបានធ្លាក់ចូលក្នុង ចិត្តរបស់អ្នក ថា "*នេះជា*ពេលវេលា"

ឥឡូវសូមយើងអធិស្ឋាន។

312 ព្រះអង្គជាទីស្រលាញ់ ដែលបានបង្ហាញអង្គទ្រង់នៅក្នុងសាច់ឈាមជា មនុស្សក្នុងអង្គព្រះយេស៊ូព្រះគ្រីស្ទ ដែលបានរស់ពីសុគតឡើងវិញនៅថ្ងៃទីបី យោងទៅតាមបទគម្ពីរ ហើយបានឡើងទៅស្ថានខ្ពស់ ហើយចាត់ពួកសិស្ស អោយទៅឯលោកិយទាំងមូល ហើយបានមានបន្ទូលថា "ទីសំគាល់ទាំងនេះនឹង តាមដល់អស់អ្នកដែលជឿ"

313 ព្រះជាម្ចាស់អើយ ចំពោះពួកជំនុំពេនទីកុស្តនៃសព្វថ្ងៃនេះ ការស្តារឡើងវិញ នៃអំណោយទាន សូមឲ្យបុរសទាំងនោះ ព្រះអម្ចាស់អើយ ប្រហែលជាពួកគេ ខ្លះ មានវត្តមាននៅទីនេះ ឯអ្នកខ្លះក្នុងចំណោមពួកគេបានស្តាប់កាសែតនៅ ជុំវិញ លោកិយទាំងមូល សូមឱ្យពួកគេដឹងថានេះគឺជាការហៅចេញរបស់កូនក្រមុំ មិនមែនជាសាររបស់ពេនទីកុស្តទេ។ សាររបស់ពួកពេនទីកុស្ត គឺដើម្បីស្តារ អំណោយទានត្រឡប់មកវិញនៅក្នុងក្រុមជំនុំ។ ប៉ុន្តែនេះគឺជាការហៅចេញនៃកូន ក្រមុំ ជាសារមួយផ្សេងទៀតដែលត្រូវមកមុនពេលក្រុងសូដុមត្រូវដុតម្តងទៀត។ សូមឱ្យពួកគេយល់ ព្រះជាទីស្រឡាញ់អើយ។ ជំនឿខ្ញុំជឿរឿងនេះពីព្រោះវាត្រូវ បាន បង្ហាញឱ្យឃើញដោយព្រះវិញ្ញាណរបស់ទ្រង់តាមរយៈព្រះបន្ទូលព្រះជាម្ចាស់ ហើយបានសម្តែងភាពត្រឹមត្រូវហើយបង្ហាញដល់លោកិយទាំងមូល។ ពិតប្រាកដ ណាស់ ព្រះអម្ចាស់អើយ នៅក្នុងមនុស្សភាគតិចតែងតែជាក្រុមរបស់ ទ្រង់។ ប៉ុន្តែ ទ្រង់បានមានបន្ទូលថា "កុំខ្លាចអី ក្រុមតូចអើយ វាជាព្រះហឫទ័យ ព្រះវបិតារបស់ អ្នក ដែលបានប្រទានអាណាចក្រនេះដល់អ្នក។"

314 ដូច្នេះ ទូលបង្គំអធិស្ឋានថា មនុស្សនឹងមើលឆ្ងាយពីបញ្ហារបស់ពួកគេ ហើយសម្លឹងពីអ្វីដែលពួកគេអាចគិតថាត្រឹមត្រូវ ហើយមើលទៅបទគម្ពីរ។ ហើយដូចបាននិយាយកាលពីយប់មិញ សូមឱ្យមនុស្សនៅទីនេះគិតដូច មហាក្សត្រិយានីបានធ្វើនៅក្នុងថ្ងៃនៃការបំផ្លិចបំផ្លាញដ៏ធំនៃបាប៊ីឡូន នាងបាន និយាយថា "មានបុរសម្នាក់ក្នុងចំណោមអ្នកដែលមានឈ្មោះថា 'ដានីយ៉ែល' គឺស្ថិតនៅក្នុងនគររបស់បិតាអ្នក។ (ឪពុករបស់ពួកពេនទីកុស្ត គឺនៅក្នុងនគរ របស់ទ្រង់។) ហើយគាត់គឺជាអ្នកបើកសម្តែងរាល់ការសង្ស័យ។"

315 ហើយឥឡូវនេះ ព្រះអម្ចាស់អើយ សូមឱ្យព្រះវិញ្ញាណបរិសុទ្ធដែលមាននៅក្នុងពួកពេនទីកុស្ត ជានគរដែលលោកម៉ាទីនលូធើនៅ របស់ចនវេសលីហើយនិង—ហើយទៅដល់ចនស៊ីធនិង អាលីសាន់ឌើខាមបែល និងតាមសម័យកាលនីមួយៗ។ ទ្រង់ជាអ្នករំលាយ ជាអ្នកបើកសម្តែងគំនិតមនុស្សនៅថ្ងៃ របស់លូធើរ ក្នុងបុរសម្នាក់នោះថា "មនុស្សសុចរិតរស់នៅដោយជំនឿ។" ពួកមេតូឌីសទ្រង់បានរំលាយរាល់ការសង្ស័យទាំងអស់គឺថា "ពួកគេគួរតែ—ពួកគេគួរតែត្រូវបានញែកជាបរិសុទ្ធ។" ហើយទៅសម័យកាលពួកពេនទីកុស្ត ពួកគេបាននិយាយភាសាដទៃ បានបើកសម្តែងពីព្រះវិញ្ញាណតាមរយៈព្រះការ ប្រោសឲ្យជា និងអ្វីៗផ្សេងទៀតវាបានរំលាយរាល់ការសង្ស័យទាំងអស់ នៅក្នុងចិត្តនៃពួកពេនទីកុស្ត។ ប៉ុន្តែ ឱព្រះអង្គអើយ ពួកគេជានិកាយ។ ពួកគេបានចេញទៅក្រៅដើម្បីទទួលយកគំនិតរបស់មនុស្ស។ ដូច្នេះ ឥឡូវនេះនៅពេលដែលកូនក្រមុំត្រូវបានត្រាស់ហៅ ដូចជាទ្រង់បានសន្យា វានៅទីនេះក្នុងបទគម្ពីរ បាបអានវាចំពោះលោកិយ ពីមួយយប់ទៅមួយយប់ ហើយយើងមើលវាដោយភ្នែករបស់យើង។ ព្រះអង្គអើយ សូមឲ្យវាអាចរំលាយ ការសង្ស័យនៅក្នុងចិត្តរបស់មនុស្ស។ សូមឱ្យពួកគេរត់គេចទៅរកបុត្រាដែល បើកចំហ ដែលទុំ ដែលត្រូវនាំយកទៅធ្វើជាពូជមិនត្រូវដូចជាសំបក ដែលទុកចោលហើយត្រូវបានដុតបំផ្លាញឡើយ ប៉ុន្តែពួកគេអាចក្លាយជាពូជល្អ នៅយប់នេះ។ នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន។

សូមអរគុណចំពោះការយកចិត្តទុកដាក់របស់លោកអ្នក។ សូមឱ្យព្រះដោះស្រាយជាមួយដួងចិត្តរបស់អ្នក។

316 ឥឡូវនេះ តើអ្នក...យើងមានប័ណ្ណអធិស្ឋាន។ ឥឡូវយើងចែកទៅហើយត្រូវចំណាយពេលប្រហែលជា២០នាទីសម្រាប់អធិស្ឋាន។ យើងចង់តម្រង់ជួរ សូម

ប្រញាប់ឡើងហើយឆ្លងកាត់វេទិកាហើយអធិស្ឋាន។ ហើយឥឡូវនេះ ខ្ញុំមិនដឹងពីចំនួនកាតប៉ុន្មានទេដែលត្រូវបានចែកអោយ។ ខ្ញុំមិនដែលសួរប៊ីលលី សោះ។ ខ្ញុំគ្រាន់តែនិយាយថា "តើអ្នកបានផ្តល់កាតឱ្យ...ចូរចុះទៅទីនោះ ហើយចែកកាតអធិស្ឋានចុះ។" ហើយគាត់បានត្រឡប់មកវិញហើយនាំយកម្តាយរបស់គាត់និងខ្ញុំហើយនិងពួកគេ។ មុននេះមួយភ្លែត។ ឥឡូវខ្ញុំ—ខ្ញុំបានធ្វើ...

317 តើអ្នកចាប់ផ្តើមពី១០០ចុះមក១ឬពី១ឡើងទៅ១០០ឬក៏យ៉ាងម៉េច? ប្រងប្រុសប៊ីលលីប៉ូលនិយាយថា "ពី១ទៅ១០០"—។]មួយទៅមួយរយត្រឹមត្រូវហើយ។

318 សូមលើកប័ណ្ណអធិស្ឋានលេខ១។ បើអ្នកមានសូមលើកដៃឡើងដូច្នេះ ខ្ញុំអាចមើលឃើញអ្នក។ បើអ្នកមិនអាច...បើអ្នកអាចក្រោកឈរឡើងបាន... បើអ្នកមិនអាចឈរបានយើងនឹងគ្រាអ្នក។ កាតអធិស្ឋានលេខមួយសូមប្រញាប់។ អ្នកណាមានកាតនោះ? តើនិយាយថាម៉េច? កាតអេលេខមួយ។ (សូមអភ័យទោស) លេខ...ស្ត្រីនៅទីនេះតើអ្នកមានកាតនោះឬ? សូមមកទីនេះ ស្ត្រីអើយតើអាចមកបានទេ? កាតអេលេខពីរ។ តើអ្នកមានវាទេ តើនរណាម្នាក់មាន? លើកដៃរបស់អ្នកអោយលឿន។ ស្ត្រីនៅទីនេះសូមមក។ លេខបី។ មានកាតទេ? តើអ្នកមានប័ណ្ណទេ? អ្នកទាំងអស់គ្នាគ្មានកាតណាមួយ ទេឬ? អូ? មិនអីទេ អ្នកមិនចាំបាច់មានទេវា។ កាតអេបី បួន ប្រាំ។ មួយ ពីរ បី បួន ប្រាំ។ ឃើញទេមានមួយ ពីរ បី បួន ប្រាំ។ មួយ...ពួកគេនៅទីនេះ... ប្រាំ ប្រាំមួយ ប្រាំពីរ ប្រាំបី ប្រាំបួន ដប់។ មិនអីទេ គ្រាន់តែតម្រង់ជួរ គ្រាន់តែចាប់ផ្តើមតម្រង់ជួរ។

319 ឥឡូវនេះ បើអ្នកមិនអាចមកបានទេ សូមគ្រវីដៃរបស់អ្នក ដូច្នេះពួកគេអាចគ្រាអ្នកបាន។ ខ្ញុំបានសួរមនុស្សទាំងនេះនៅទីនេះដែលមិនមានកាត...មិនចាំបាច់មានវាទេខ្ញុំគ្រាន់តែសួរអ្នកប៉ុណ្ណោះ។ ឥឡូវនេះមើល អ្នក—អ្នកពិការនៅទីនេះ ខ្ញុំស្មានថាគាត់ត្រូវតែមកមុនគេ" ពីព្រោះគ្រាន់ ខ្ញុំទើបតែប្រាប់គាត់ថា "មកប្រញាប់។" ឥឡូវនេះ អ្នកមិនចាំបាច់មានកាតទេបើអ្នកមានជំនឿដូចខ្ញុំ បានបង្រៀន។ ឃើញទេ បើវាត្រូវបានបើកសម្តែងដល់អ្នក។ តែបើវាមិនត្រូវបាន បើកសម្តែងទេ មិនថាអ្នកនៅក្នុងជួរនៃការអធិស្ឋានរាប់សិបដង វានឹងមិនជួយអ្វី បន្តិចសោះដល់អ្នក។ អ្នកដឹងទេ? តើអ្នកជឿទេ? ឃើញទេ? ខ្ញុំអាចអធិស្ឋាន ខ្ញុំខំអស់ពីសមត្ថភាពដែលខ្ញុំអាចធ្វើបាន ទាំងលុតជង្គង់ហើយដាក់ដៃលើអ្នក ចាក់ប្រេងលើអ្នកឬអ្វីដែល

អ្នកចង់បាន ហើយអធិស្ឋាន។ ដរាបណាព្រះជាម្ចាស់ ដោយសារ...ព្រះគុណ បង្ហាញថានៅក្នុងចិត្តរបស់អ្នកថា "វាចប់ហើយ" បន្ទាប់មកវានឹងរួចរាល់។ អ្នកមិនចាំបាច់នៅក្នុងជួរអធិស្ឋាន ឬកន្លែងណាក៏ដោយ ទោះជាយ៉ាងណាវារួចរាល់ហើយ។

320 ត្រូវហើយ បួន...មួយ ពីរ បី បួន ប្រាំ ប្រាំមួយ ប្រាំពីរ ប្រាំបី ប្រាំបួន ដប់ ដប់មួយ ដប់ពីរ ដប់បី ដប់បួន ដប់ប្រាំ។ មិនអីទេ ដប់ប្រាំមួយ ដប់ប្រាំពីរ ដប់ប្រាំបី ដប់ប្រាំបួន ដប់ប្រាំពីរ ម្ភៃ។ តើមាននរណាម្នាក់ដែលខ្ញុំហៅ ហើយមានកាត់តែមិនអាចក្រោកឈររួចឬទេ? លើកដៃរបស់អ្នកឡើង មានកាតតែមិនអាចក្រោកឈរឡើងបាន។ មិនអីទេ។

...គ្រាន់តែជឿតាម

ខ្ញុំអាចមើលឃើញក្មេងកំសត់អាណាយ៉ានណេកំពុងអង្គុយលេងរាល់យប់នោះជិតដល់ពេលមួយ។ ខ្ញុំចង់ឲ្យអ្នករាល់គ្នាមានភាពស្ងប់ស្ងាត់និងការគោរពដូចអ្នកដឹងហើយ។

...គ្រាន់តែជឿតាម

ឥឡូវនេះ កាតអធិស្ឋានពីមួយទៅដប់ប្រាំ ខ្ញុំជឿថាវាអញ្ចឹង។

...គ្រាន់តែជឿតាម

ពួកគេមានមនុស្សច្រើននៅទីនេះ ដូច្នេះសូម—សូមចាប់ផ្តើម។ តើអ្នកនិយាយថាម៉េច?

...អាចទៅបាន...

321 មួយ ពីរ បី បួន ប្រាំ ប្រាំមួយ ប្រាំពីរ ប្រាំបី ប្រាំបួន ដប់...ឥឡូវ អ្នកកំពុងមានគ្នាច្រើនពេក។ លើសពីអ្វីដែលយើងបានហៅទៅទៀត។ វាមិនអីទេ។ ឈរនៅកន្លែងរបស់អ្នកចុះ។ កុំឲ្យនរណាម្នាក់គ្រាន់តែ...អ្នកនឹង ទទួលបាន...អ្នកនឹងបានអធិស្ឋានឲ្យ ប៉ុន្តែគ្រាន់តែ...ឃើញទេ សូមរង់ចាំរហូត ដល់ពួកគេហៅលេខរបស់អ្នក។ បន្ទាប់មក អ្នកដឹងទេយើង—យើងមិនអាច ឈរច្រើនពេកទេនៅទីនេះ។ បើព្រះអម្ចាស់ទ្រង់ធ្វើអ្វីមួយ អ្នកបានបិទពីមនុស្ស ហើយពួកគេអ្នកមិនអាចមើលឃើញវាបានទេ អ្នកឃើញទេ។ សូមព្រះប្រទានពរ។

ឥឡូវសូមអធិស្ឋានសម្រាប់កន្សែងដៃទាំងនេះ នៅពេលពួកគេបានត្រៀមរួចរាល់។

322 ព្រះអង្គជាទីស្រលាញ់ កន្សែងដៃដាក់នៅទីនេះដែលបានមកពីអ្នកជំងឺ និងអ្នករងទុក្ខ។ ជំនឿដែលយើងទើបនឹងនិយាយអំបាញ់មិញនេះ ព្រះអង្គអើយ! ទូលបង្គំចាំថា ទ្រង់មានបន្ទូលនៅក្នុងព្រះគម្ពីរយូដាស "មានជំនឿដោយស្មោះត្រង់តស៊ូដើម្បីប្រគល់ទៅពួកបរិសុទ្ធ។" ហើយពីរាងកាយរបស់ពួកបរិសុទ្ធពួកគេបានយកកន្សែងដៃ មិនមែនដោយសារពួកគេជាមនុស្សពិសេសទេ ប៉ុន្តែដោយសារតែពួកគេជាមនុស្សដែលជឿ។ ពួកគេជាមនុស្សមានចិត្តរាបទាប ដូចជាយើងដែរ។ ពួកគេនិយាយថា "អេលីយ៉ាគឺដូច្នោះដែរ គាត់បានអធិស្ឋាន ដោយស្មោះថានឹងគ្មានភ្លៀង។" ហើយ ព្រះជាម្ចាស់អើយ គាត់បានអធិស្ឋាន *បែបនោះ*ក៏ដោយសារតែចង់ឲ្យមនុស្សប្រែចិត្ត។ ទ្រង់បានបង្ហាញឱ្យគាត់អធិស្ឋានសម្រាប់ពួកគេ តាមរបៀបនោះ ដើម្បីបំពេញនូវព្រះបន្ទូលរបស់ទ្រង់។ គ្មានការសង្ស័យទេដែលទ្រង់បានបង្ហាញនិមិត្តដល់ហោរា។ ហើយនៅយប់នេះ ព្រះអង្គអើយ ទូលបង្គំកំពុងអធិស្ឋានសម្រាប់មនុស្សទាំងនេះ ដើម្បីឱ្យបានជាសះស្បើយ។ ទូលបង្គំមិនមែនជាអេលីយ៉ាទេ គាត់ត្រូវបាននាំយកទៅស្ថានសួគ៌ តែជីវិតរបស់គាត់ហើយព្រះវិញ្ញាណនៅតែមាន។ ដូច្នេះយើងអធិស្ឋាន ថាទ្រង់នឹងសព្វព្រះទ័យនិងការអធិស្ឋានរបស់រាស្ត្រទ្រង់។ ហើយសព្វព្រះទ័យដល់យើងទាំងអស់គ្នានៅពេលដែលយើងអធិស្ឋាន ចំពោះកន្សែងដៃនេះ នៅពេលវាបានដាក់លើអ្នកជំងឺនោះនឹងបានជាសះស្បើយ។

323 យើងដឹងថា ព្រះវរបិតាអើយ យើងគឺជាជំនាន់—មនុស្សស្លាប់។ យើងកំពុងធ្វើដំណើរ...ប្រឈមមុខ—នឹងភាពអស់កល្ប។ លោកិយបានទៅដូចជាឆ្កួត។ ឃាតកម្ម ក្មេងស្រីតូចៗត្រូវគេកាប់ជាបំណែកៗ និងត្រូវគេបំផ្លាញ។ បុរសទុកសក់វែងដូចជាស្ត្រី ស្ត្រីដូចជាបុរសដែរ ពួកគេធ្វើឱ្យខូចអាក្រក់។ កំណើនកំពុងស្លាប់។ លោកិយកំពុងស្លាប់។ អ្វីគ្រប់យ៉ាងដែលគួរអោយគោរព។ ព្រះវិហារកំពុងស្លាប់។

324 ឱព្រះជាម្ចាស់អើយ សូមនាំមកនូវជីវិត។ នាំមកនូវជីវិត ឱព្រះជាម្ចាស់អើយ ជីវិតនៃសេចក្តីជំនឿ។ សូមបង្ហាញដល់មនុស្សទាំងនេះព្រះអម្ចាស់។ ទូលបង្គំអាចត្រឹមតែអធិស្ឋានហើយដាក់ដៃលើពួកគេ។ ប៉ុន្តែទ្រង់តែមួយដែលអាច ព្យាបាល

ពួកគេបាន ហើយមានតែព្រះអង្គទេដែលអាចប្រោសពួកគេបាន។ ទូលបង្គំអធិស្ឋានថាទ្រង់នឹងឆ្លើយតប ព្រះវរបិតាអើយ ដល់អ្នកទាំងអស់គ្នា។ សូមទ្រង់ប្រទានមក ដោយដៃទូលបង្គំបានដាក់លើពួកគេ ទូលបង្គំសូមដោយ អស់ពីចិត្ត។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ សូមទ្រង់ប្រោសមនុស្សទាំងនេះ ឲ្យជាសះស្បើយ។ អាម៉ែន។

325 ឥឡូវនេះ តើមេក្រូនេះនៅឮឬទេបងប្អូន? ឥឡូវអ្នកលឺហើយមែនទេ? អ្នករាល់គ្នាស្តាប់ឮទេ? សូមលើកដៃឡើង។ មិនអីទេ។ ឥឡូវនេះ ដូចម្តេចឬមួយផ្សេងទៀត បេះដូងរបស់ខ្ញុំមានទៅកាន់មនុស្សទាំងនេះនៅទីនេះ ដែលអង្គុយនៅទីនេះក្នុងកៅអី និងរទេះរុញទាំងនេះ...ពួកគេថែមទាំងមិនបាន ទទួលកាតអធិស្ឋានទៀតផង។ ឃើញទេ? ប៉ុន្តែ មើលបងប្រុសអើយ ឃើញមនុស្សទាំងនេះទទួលបានប័ណ្ណអធិស្ឋាន ប៉ុន្តែនោះមិនមានន័យថាពួកគេ ត្រូវបានប្រោសឲ្យជានោះទេ។ មនុស្សដែលកំពុងអង្គុយនៅក្នុងទស្សនិកជននេះ ប្រហែល—នោះ—មិនមានន័យថាពួកគេ—ពួកគេ—ពួកគេនឹងត្រូវបានជាសះ ស្បើយនោះទេ។ នោះ—មិនបាននិយាយថា—ថាពួកគេនឹងឬនឹងមិនជានោះទេ។ វាអាស្រ័យលើជំនឿរបស់ពួកគេលើព្រះ។ តើមានមនុស្សប៉ុន្មាននាក់ដឹងថាវា ជាការពិតទេ? ទាំងអស់នោះ គ្រាន់តែជាជំនឿរបស់ពួកគេលើព្រះប៉ុណ្ណោះ។ មែនហើយ តើមានបងប្អូនប៉ុន្មាននាក់ដឹងថាវាជាការពិត? មិនថាអ្នកកាន់ភ្ជាប់បែប ណាក៏ដោយឬតើអ្នកល្អឬអាក្រក់ប៉ុណ្ណា លើកលែងតែព្រះគុណរបស់ព្រះធ្លាក់ ចូលក្នុងបេះដូងអ្នក មិនដូច្នោះទេអ្នកនឹងមិនជាឡើយ។ ឥឡូវនេះ តើមានមនុស្សប៉ុន្មានដឹងថាព្រះបានធ្វើវា បានធ្វើវារហូតមក ទាំងការអស្ចារ្យ និងសេចក្តីសញ្ញានិងភាពអស្ចារ្យ? ហើយឥឡូវនេះ អ្នកបានមកនៅយប់នេះ ដោយឈរនៅក្នុងជួរនេះ មិនមែនដោយសារព្រះបានជ្រើសរើសអ្នកឱ្យឈរនៅ ក្នុងបន្ទាត់នេះទេ។ អ្នកទើបតែទទួលបានប័ណ្ណអធិស្ឋាន គ្រាន់តែបានកើតឡើង នៅកន្លែងរបស់អ្នកនៅ [បាត់សម្លេង កាសែត—Ed។]

326 នីតិវិធីគឺពិតជាដូចបងប្រុសដ៏គួរឲ្យគោរពរបស់ ខ្ញុំឈ្មោះគើហ្វលស៊ើរនៅទីនេះគាត់បានចាប់ផ្តើមព័ន្ធកិច្ចរបស់គាត់ជាច្រើនឆ្នាំមកហើយ។ [ចំណុច ទទេ នៅ លើ ខ្សែអាត់—Ed] ...ដោយជំនឿលើព្រះ ជឿព្រះ ជឿថាព្រះបាន ប្រោសអ្នក ជម្ងឺដោយ ជំនឿ។ ហើយទ្រង់មិនដែលផ្លាស់ប្តូរទេ ប៉ុន្តែព្រះបានបន្ថែមនៅ

ថ្ងៃចុង ក្រោយនេះ គឺអំណោយដែលទ្រង់បានសន្យា។ ព្រះជាម្ចាស់ទ្រង់បានធ្វើវា...មិនមែន ទ្រង់ ត្រូវតែធ្វើនោះទេ ប៉ុន្តែដោយសារទ្រង់បានសន្យា។ ហើយបើទ្រង់ បានសន្យា បន្ទាប់មកទ្រង់ត្រូវតែធ្វើវា។ ពីព្រោះទ្រង់ត្រូវតែរក្សាព្រះបន្ទូលរបស់ ទ្រង់។

327 ហើយទ្រង់បានសន្យានឹងអ្នកដូចគ្នានោះគឺ "បើអ្នកជឿនោះវានឹងកើតឡើង" បើអ្នកមិនជឿវាទេ វានឹងមិនកើតឡើងទេ។ ឥឡូវនេះ ខ្ញុំមិនអាចធ្វើឱ្យអ្នកជឿទេ ហើយអ្នកក៏មិនអាចធ្វើឱ្យខ្លួនអ្នកជឿបានដែរ។ ព្រះត្រូវតែប្រគល់វាអោយអ្នក។ វាជាអំណោយរបស់ព្រះដែលអ្នកជឿ។ មិនមែនជំនឿរបស់អ្នកទេ ជានឿរបស់ ព្រះ។ ជំនឿបញ្ញារបស់អ្នកអាចជឿថាវាល្អ ប៉ុន្តែលើកលែងតែសេចក្ដីជំនឿរបស់ព្រះ បានធ្លាក់ក្នុងចិត្តរបស់អ្នក...ឃើញទេ សេចក្ដីជំនឿបញ្ញារបស់អ្នកអាចធ្វើទៅបាន ធ្វើវាទៅ។ ហើយគ្រាន់តែជឿវាដោយអស់ពីដួងចិត្តរបស់អ្នករហូតដល់ព្រះ ជាម្ចាស់បានបើកសម្ដែងវាដល់អ្នកហើយ។ ឃើញទេ? ចូរបន្តជឿរហូតដល់ព្រះ បង្ហាញវា។ ប៉ុន្តែរហូតដល់ទ្រង់បានបង្ហាញវា...

328 អ្នកនិយាយថា "បងប្រុសប្រាណហាំ តើអ្នកនិយាយអ្វីនៅទីនោះ?"

329 "មែនហើយ!" ព្រះបានបញ្ជូនហោរាម្នាក់ទៅឯហេសេគាហើយប្រាប់គាត់ថា "'អ្នកនឹងមិនងើបពីគ្រែនោះបានទេ' **នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់**។ 'អ្នកនឹងស្លាប់នៅលើគ្រែនោះ។'" ហ្នឹងហើយ?

330 ប៉ុន្តែហោរានោះបានបែរមក...ឬស្ដេចនោះបែរមុខទៅជញ្ជាំង គាត់ស្រែក អួលទាំងទឹកភ្នែកថា "ព្រះអម្ចាស់ ទូលបង្គំត្រូវការពេលដប់ប្រាំឆ្នាំទៀត។ ឱព្រះ អម្ចាស់អើយ សូមទ្រង់ព្រះសណ្ដាប់ទូលបង្គំផង" ឥឡូវនេះ ស្ដេចគឺអស្ចារ្យ ជាងមនុស្សទាំងអស់នៅលើលោកិយនៅក្នុងនយោបាយ ប៉ុន្តែហោរាបានធំនៅក្នុង ព្រះនេត្ររបស់ព្រះ។ នោះគឺជាស្ដេចរបស់ព្រះជាម្ចាស់។ ប៉ុន្តែវាជាហោរារបស់ព្រះ។ ដូច្នេះ ព្រះបានបង្ហាញឱ្យហោរាយក...ស្ងោរ... [បាត់សម្លេង—ការសែត] អ្នកដឹងទេ អ្នកយល់ទេ?

331 ឥឡូវនេះ អ្នកប្រហែលជាយល់ហើយ ពីព្រោះខ្ញុំបានអធិប្បាយព្រះគម្ពីរ នៅទីនេះ "ដូចនៅក្នុងថ្ងៃនៃក្រុងសូដុមដែរ នោះកូនមនុស្សនឹងយាងមកម្ដងទៀត" នៅក្នុងថ្ងៃដែលក្រុមជំនុំកំពុងត្រូវបានបើកសម្ដែងឱ្យស្គាល់? អត់ទេ! "នៅថ្ងៃដែលកូនមនុស្សលេចមក" អ្វីដែលត្រូវបាន*លេចមក*? បើកសម្ដែងឱ្យគេស្គាល់! ត្រូវ

ហើយបើកសម្តែង! ថ្ងៃដែលកូនមនុស្សបានបើកសម្តែង វានឹងជាថ្ងៃ ដូចជា ក្រុងសូដុមនិងកូម៉ូរ៉ាដែរ។ តើវាត្រូវទេ?

332 ឃើញទេ តើមានអ្វីកើតឡើង។ ពួកគេមានអ្នកនាំសារសំខាន់ពីរចុះនៅទីនោះនៅក្រុងសូដុំមនិងកូម៉ូរ៉ា ពីព្រោះមានក្រុមមួយជាពួកគ្រីស្ទានមិនក្តៅមិនត្រជាក់នៅទីនោះ។ តើវាត្រូវទេ? ហើយពួកគេមានអ្នកនាំសារសំខាន់ៗពីរ (ឥឡូវស្តាប់អោយបានច្បាស់) នៅក្រុងសូដុមនិងកូម៉ូរ៉ា បានផ្សព្វផ្សាយ ព្រះបន្ទូល។ ប៉ុន្តែម្នាក់ក្នុងចំនោមពួកគេដែលឈរនៅទីនេះជាមួយក្រុមអ័ប្រាហាំ ត្រូវហើយ?

333 ឥឡូវនេះមើល! យើងមិនដែលមាននៅក្នុងប្រវត្តិសាស្ត្ររបស់ក្រុមជំនុំឡើយមានអ្នកនាំសារជាសកលដល់ក្រុមជំនុំដែលឈ្មោះរបស់គាត់បានបញ្ចប់ដោយ ហ—ា—ំរហូតមកដល់ពេលនេះ:ក្រ—ា—ហ—ា—ំដែលមានអក្សរ ចំនួន៦គឺ ក្រ—ា—ហ—ាំ។ ប៉ុន្តែ អ័ប្រាហាំឈ្មោះត្រូវបានសរសេរ អ—័—ប្រ—ា—ហ—ាំអក្សរ៧។ ឃើញទេ? ដូច្នេះក្រុមជំនុំជាសកលតែងមានឈ្មោះរបស់មនុស្សប្រាំមួយអក្ស ជាអង្គការដែលមនុស្សបង្កើត តែបានទទួលអ្នកនាំសាររបស់ពួកគេ។ ពួកគេមាន សាន់ហ្គីរ ម៉ូឌី ហ្វីននី ណុក កាល់វិន ជាដើម ប៉ុន្តែមិនដែលមាន "ហ—ា—ំ" ឡើយ។ តើវាត្រូវទេ? ប៉ុន្តែពួកគេបានទទួលវាហើយគាត់គឺជាអ្នកនាំសារដែលត្រូវបានបញ្ជូនមកពីព្រះ ហើយគាត់កំពុងតែធ្វើឱ្យពួកគេមានកំផែងជញ្ជាំងដូចដែលគាត់អាចធ្វើបាន "ចេញពីទីនេះ! ចង់ប្រែចិត្តឬក៏ចង់វិនាសទៅ!

334 ប៉ុន្តែសូមចាំថា អ្នកដែលបានរើសតាំងដែលបានតំរូវទុកជាមុននិងមាន កិច្ចព្រមព្រៀងមុន។ ជាអ័ប្រាហាំនិងក្រុមរបស់គាត់ក៏មានអ្នកនាំសារផងដែរ។ អ៊ូ—ហ៊ូ។ មើលអ្វីដែលគាត់បានធ្វើ។ ទ្រង់បានផ្តល់ឱ្យពួកគេនូវសញ្ញាថា ពេលវេលាជិតដល់ហើយដែលភ្លើងនឹងឆេះ។ ឥឡូវនេះ យើងកំពុងរកមើលភ្លើង អាតូមិកគឺជាកំហឹងរបស់ព្រះ។

335 ឥឡូវនេះ អ្នកនាំសារនោះបានធ្វើអ្វីមួយ។ ទ្រង់មានបន្ទូលពីស្ត្រីម្នាក់ដែលទ្រង់បានបែរខ្នងដាក់ ហើយបានប្រាប់នាង—ហើយបានប្រាប់នាងពីអ្វីដែលនាងនៅសង្ស័យពីអ្វីដែលទ្រង់កំពុងមានបន្ទូលប្រាប់ពីស្ថានភាពរបស់នាងនិងអ្វីដែលបានកើតឡើងថានឹងកើតឡើង។ តើវាត្រូវទេ? តើទ្រង់បាននិយាយថាកូនមនុស្ស

នឹងបង្ហាញអង្គទ្រង់តាមរបៀបដូចគ្នានៅថ្ងៃនោះ? អញ្ចឹង តើអ្នកជឿថានោះ ជាការពិតទេ?

មែនហើយ ស្ត្រីម្នាក់ឈរនៅទីនេះ...

336 ហើយនៅក្នុងសហជីពដែលមើលមិនឃើញ នៃក្រុមជំនុំកូនក្រមុំព្រះគ្រីស្ទ អ្នកនាំសារគឺនៅទីនេះ ដែលជាព្រះយេស៊ូវគ្រីស្ទដូចគ្នាកាលពីម្សិលមិញថ្ងៃនេះ និងជារៀងរហូត។

337 ឥឡូវនេះ ទ្រង់គ្រាន់តែនិយាយតាមរយៈហោរារបស់ទ្រង់។ ព្រះគម្ពីរបានចែងយ៉ាងដូច្នេះ! "ទ្រង់មិនធ្វើអ្វីសោះឡើយ លើកលែងតែទ្រង់បាន បង្ហាញដល់ហោរារបស់ទ្រង់ជាមុនសិន" អេម៉ុស៣:៧។ ទ្រង់តែងតែធ្វើវា។ ទ្រង់មិនដែលផ្លាស់ប្តូរគំរូរបស់ទ្រង់ទេ។ ឃើញទេ? ហើយហោរាអាចនិយាយបាន លុះត្រាតែគាត់ និយាយអ្វីដែលព្រះប្រាប់គាត់។ គឺត្រូវហើយ? វាជាការពិត។

338 ឥឡូវនេះ តើអ្នកជឿថាទ្រង់អាចប្រាប់ខ្ញុំពីបញ្ហារបស់ស្ត្រីម្នាក់នេះមុនពេលដែលខ្ញុំមើលទៅមុខនាងផងឬទេ? តើអ្នកជឿទេ? ហេតុអ្វី នាងបានទទួល រងនូវជំងឺមហារីក។ ត្រឹមត្រូវហើយ។ វាស្ថិតនៅលើសុដន់របស់នាង។ នាងមានកូនប្រុសម្នាក់ នៅក្នុងគំនិតរបស់នាង គាត់បានទទួលរងជាមួយនឹង ប្រភេទនៃស្ថានភាពផ្លូវចិត្តមួយ ភ័យខ្លាចនិងផលវិបាក។ ត្រឹមត្រូវហើយ។ តើអ្នកជឿទេ? ហើយនោះជាការពិត មែនទេ? តើអ្នកជឿថាសេចក្តីជំនឿរបស់អ្នក ដោយនិយាយបែបនេះដែលបានបោះយុថ្កាថាអ្នកបានទទួលវា អ្នកនឹងមានវាទេ? បន្ទាប់មក ចូរចេញទៅ ព្រះអម្ចាស់យេស៊ូនឹងប្រោសអោយអ្នកបានជា។ ឃើញទេ? មែនហើយ។ ឃើញទេ? តើអ្នកជឿទេ? ជឿអស់ពីចិត្ត?

339 ឥឡូវនេះ តើអ្នកជឿទេ ដោយមិនចាំបាច់មើលមុខស្ត្រីម្នាក់នេះទេ តែព្រះអម្ចាស់ព្រះយេស៊ូវអាចប្រាប់ខ្ញុំថានាងមានបញ្ហាអ្វី? តើមានប៉ុន្មាននាក់ជឿ? ឥឡូវនេះ អ្នកដឹងទេ...ហើយខ្ញុំមិនដែលសូម្បីតែ...ខ្ញុំ...រឿងតែមួយគត់ ខ្ញុំបានឃើញតែសំពត់។ ខ្ញុំមិនដឹងទេ ខ្ញុំមិនអាចប្រាប់បានទេថាតើវាជាបុរស ឬស្ត្រី។ ប៉ុន្តែគ្រាន់តែឈរនៅទីនោះ។ ខ្ញុំចង់ឲ្យនាងជឿ។ តើអ្នកជឿទេលោកស្រី? នៅទីនេះ អ្នកជំងឺ តើអ្នកជឿទេ? លើកដៃរបស់អ្នកឡើងបើអ្នកជឿ។ បើអ្នកជឿអស់ពីចិត្តអ្នកអាចមានកូននោះដែលអ្នកកំពុងស្នើសុំព្រះ។ ឃើញទេ? ឃើញទេ? អ្នកជឿទេ? តើអ្នកមានជំនឿលើព្រះទេ? ឥឡូវ វាមិនអាចជាសះស្បើយទេ តែត្រូវបង្ហាញពីជំនឿ។

នោះគឺជាកិច្ចការដែលបញ្ជាក់ពី ជំនឿរបស់វត្តមានរបស់ព្រះជាម្ចាស់ ព្រះបន្ទូលរបស់ទ្រង់បើកសម្តែងឲ្យឃើញ។

340 ស្ត្រីនេះក៏ចង់បានរបស់ដ៏អស្ចារ្យដែរ។ នោះមិនមែនជាកូនទេ នាងចង់បានបុណ្យជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ។ ខ្ញុំនឹងប្រាប់អ្នកពីអ្វីដែលត្រូវធ្វើៈ បើអ្នកនឹងឈប់ពីការជក់បារី ព្រះជាម្ចាស់នឹងអោយអ្នកទទួលបុណ្យជ្រមុជទឹកពីព្រះវិញ្ញាណបរិសុទ្ធ។ ចូរទៅចុះ ហើយជឿវាឃើញទេ។ តើអ្នកជឿទេ? តើអ្នកមានជំនឿលើព្រះទេ?

341 បុរសម្នាក់ដែលឈរនៅទីនេះ គឺជាបុរសដែលខ្ញុំមិនធ្លាប់បានឃើញនៅក្នុងជីវិតរបស់ខ្ញុំឡើយ។ ខ្ញុំអត់ទេស្គាល់គាត់ ប៉ុន្តែគាត់កំពុងរងទុក្ខជាមួយនឹងបញ្ហានៅក្នុងទ្រូងរបស់គាត់។ គាត់ធ្លាប់ដួលដែលបានធ្វើឲ្យគាត់ក្លាយជាអញ្ជឹង មិនជាយូរប៉ុន្មានទេ។ គាត់មិនមែនមកពីទីនេះទេ គាត់មកពីរដ្ឋអាកាន់សាស។ គាត់គឺជាគ្រូអធិប្បាយ។ ចូរទៅផ្ទះ ផ្សព្វផ្សាយដំណឹងល្អ។ ឃើញទេ? ឃើញទេ? ឃើញទេ? ខ្ញុំមិនដែលឃើញមុខគាត់ទេ។

342 មានស្ត្រីម្នាក់ឈរនៅទីនេះ ខ្ញុំមិនស្គាល់ស្ត្រីនោះទេក៏មិនដែលបានឃើញ មុខនាងក្នុងមួយជីវិតរបស់ខ្ញុំសោះ។ ព្រះជាម្ចាស់ស្គាល់នាង។

343 បើទ្រង់អាចបង្ហាញពីអ្វីដែលជាបញ្ហារបស់នាងឬអ្វីមួយអំពីវា តើអ្នកជឿទេ? អ្នករាល់គ្នាជឿទេ? នេះគ្រាន់តែជាការងារមួយដែលបញ្ជាក់ពីជំនឿខ្ញុំត្រូវតែផ្សព្វផ្សាយអ្វីដែលខ្ញុំបានប្រាប់អ្នកនៅយប់នេះ។ នោះជាអ្វីដែលព្រះបានបង្ហាញឱ្យដឹងហើយនេះគឺជាការងារដែលបង្ហាញវា។ ឥឡូវនេះ អ្នកត្រូវតែមានជំនឿដើម្បីបានជាសះស្បើយ។

344 ស្ត្រីម្នាក់នៅទីនេះ ខ្ញុំមិន—ខ្ញុំមិនគិតថាខ្ញុំស្គាល់នាងទេ។ បាទខ្ញុំអត់នាងទេ ប៉ុន្តែខ្ញុំស្គាល់អ្នកណាម្នាក់ដែលនាងស្គាល់ពីព្រោះខ្ញុំឃើញគាត់ឈរនៅទីនេះមុនខ្ញុំ។ នាងមានបញ្ហាឈឺក្បាល។ តើមែនទេស្ត្រីអើយ? តើអ្នកជឿថាព្រះ នឹងប្រោសអ្នកទេ? ជាបងស្រីរបស់ភារីគ្រីន។ ហ្នឹងហើយ។ ខ្ញុំមិនដែលឃើញនាង នៅក្នុងជីវិតរបស់ខ្ញុំទេ។ ត្រឹមត្រូវហើយ។ ខ្ញុំបានឃើញភារីគ្រីនឈរនៅទីនេះ សម្លឹងមើលខ្ញុំ បែប*ដូច្នេះ*។ គ្រាន់តែមក។ ត្រូវហើយ។ ខ្ញុំមិនដឹងថាភារីគ្រីន នៅកន្លែងណាទេ។ តើអ្នកជឿទេ? តើអ្នកមានជំនឿប៉ុន្មាន? បើអ្នកអាចជឿ អ្វីៗទាំងអស់អាចធ្វើទៅបាន។ បើអ្នកមិនជឿទេ នោះគ្មានអ្វីអាចកើតឡើង បានទេ។

345 ស្ត្រីតូចម្នាក់ដែលមានសក់ពណ៌ប្រផេះ កំពុងអង្គុយសម្លឹងមើលខ្ញុំនៅទីនេះ តើអ្នកជឿព្រះទេ? តើអ្នកជឿថាព្រះអាចបង្ហាញដល់ខ្ញុំពីអ្វីដែលអ្នកកំពុងគិតទេ? មានដុំសាច់ដុះលើសុដន់។ តើអ្នកជឿថាព្រះអាចយកវាចេញពីអ្នកបានទេ? ត្រូវហើយ។ មានជំនឿនិងជឿចុះ។ ឥឡូវ តើនាងបានប៉ះអ្វី?

346 ស្ត្រីដែលបានប៉ះព្រំព្រះពស្ត្រទ្រង់ គម្ពីរបាននិយាយថា...អ្នកដែលមានព្រះគម្ពីរទ្រង់មានបន្ទូលថា "ទ្រង់គឺជាសម្តេចសង្ឃ ដែលអាចប៉ះដោយអារម្មណ៍នៃ ភាពទន់ខ្សោយរបស់យើង។" តើមិនត្រឹមត្រូវទេឬ? ទ្រង់គឺជាសម្តេចសង្ឃហើយទ្រង់កំពុងតែឈរនៅទីនេះ។ ពួកគេជាមនុស្សបានប៉ះទ្រង់។

347 មានស្ត្រីម្នាក់ដែលស្គមស្គាំងបានលើកដៃរបស់នាងឡើងនៅទីនេះ។ ខ្ញុំមិនដែលឃើញនាងនៅក្នុងជីវិតរបស់ខ្ញុំទេ ប៉ុន្តែនាងទើបតែប៉ះអ្វីមួយ។ នេះហើយជាអ្វី។ នាងបានអធិស្ឋានដល់ព្រះ។ នាងមានបញ្ហានៅក្នុង ទ្រូងរបស់នាង នាងមានបញ្ហាក្រពះផងដែរ។ ព្រះបានព្យាបាលអ្នក បើអ្នកនឹងជឿ។ អ្នកត្រូវតែជឿ។ "អ្វីទាំងអស់អាចធ្វើបានសម្រាប់អ្នកណា ដែលជឿ។"

348 មានបុរសម្នាក់កំពុងតែអង្គុយនៅខាងក្រោយ មើលតាមនេះ ក្នុងជួរទីពីរ សូមចូលមកនេះ) ដោយមានជម្ងឺហឺត។ តើអ្នកជឿថាព្រះនឹងព្យាបាលអ្នក បានទេលោក? បើអ្នកជឿនោះព្រះនឹងប្រោសឲ្យអ្នកជា។ អ្នកអាចទទួលអ្វីដែល អ្នកបានសុំ

349 មានស្ត្រីម្នាក់កំពុងតែអង្គុយនៅទីនេះ សម្លឹងមើលខ្ញុំ ឆ្លងកាត់ទីនេះ មានសក់ពណ៌ប្រផះ។ បើអ្នកជឿអស់ពីចិត្ត...តើអ្នកជឿទេ? មិនអីទេ បញ្ហាគ្រួសក្នុងថង់ទឹកប្រមាត់នឹងចាកចេញពីអ្នកបើអ្នកជឿ។

350 តើអ្នកគិតយ៉ាងណាអំពីវា ដេកនៅលើគ្រែតូច? តើអ្នកជឿថានឹងព្យាបាលអ្នកឬទេ? បើព្រះនឹងប្រាប់ខ្ញុំពីបញ្ហារបស់អ្នក តើអ្នកនឹងជឿទ្រង់ទេ? បើអ្នកជឿថាមហារីកនោះនឹងចាកចេញពីអ្នកហើយអ្នកនឹងបានជា។ ហេតុអ្វីបានជាអ្នកមិនក្រោកឡើង យកគ្រែរបស់អ្នកហើយត្រឡប់ទៅផ្ទះវិញទៅ? តើអ្នកជឿទេ? តើអ្នកទាំងអស់គ្នាជឿទេ? មែនហើយ ឥឡូវនេះ ចុះយ៉ាងណាវិញ? តើព្រះជាម្ចាស់បានចាក់សេចក្តីជំនឿនោះនៅក្នុងចិត្តរបស់អ្នកទេ? អ្នករាល់គ្នានៅទីនេះ សូមលើកដៃឡើង។ បើព្រះជាម្ចាស់ទម្លាក់ជំនឿនេះ មកក្នុងចិត្តរបស់អ្នកសូមដាក់ដៃរបស់អ្នកចុះលើម្នាក់ផ្សេងទៀតនៅខាងស្តាំ ចុះនៅតាមបណ្តោយបន្ទាត់នៅទីនេះ។ ដាក់ដៃ

របស់អ្នកលើ...ឥឡូវនេះ សូមប្រញាប់ ព្រះវិញ្ញាណបរិសុទ្ធកំពុងតែធ្វើចលនា សូមដាក់ដៃរបស់អ្នកលើ ម្នាក់ផ្សេងទៀត។ បុរសនោះកំពុងរត់ហើយកំពុងអធិស្ឋានសំរាប់អ្នកដទៃ។

351 ចូរក្រោកឈរឡើងហើយសរសើរតម្កើងព្រះជាម្ចាស់នៃអ្នករាល់គ្នា។ មិនត្រូវការធ្វើដំណើរទៅមុខទៀតទេ។ កំណត់អត្តសញ្ញាណថា ព្រះយេស៊ូវគ្រីស្ទដូចគ្នាកាលពីម្សិលមិញ ថ្ងៃនេះនិងជារៀងរហូត។ អ្នក អ្វីដែលអ្នកមានទុក្ខព្រួយអ្វីក៏ដោយ បើអ្នកជឿលើទ្រង់ សូមក្រោកឈរឥឡូវនេះហើយជឿចុះ។

352 ព្រះដែលមានគ្រប់ព្រះចេស្តា ជាព្រះនៃអ័ប្រាហាំ ជាព្រះរបស់អ៊ីសាក ជាព្រះនៃយ៉ាកុបអើយ សូមបញ្ជោញអំណាចរបស់ទ្រង់មក ហើយព្យាបាលមនុស្សមួយក្រុមនេះ ឥឡូវនេះ នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន។

ថ្វាយសិរីល្អដល់ព្រះ! សូមព្រះប្រទានពរ។

# ការប្រព្រឹត្តគឺសម្តែងពីជំនឿ KHM65-1126

(Works Is Faith Expressed)

សារដែលធ្វើឡើងដោយបងប្រុស William Marrion Branham នេះ ត្រូវបានចែកចាយនៅល្ងាចថ្ងៃសុក្រ ថ្ងៃទី 26 វិច្ឆិកា1965 នៅរោងឧបោសថជីវិត ក្នុងទីក្រុងស្រើវផត, Louisiana U.S.A។ រាល់ការខិតខំត្រូវបានធ្វើឡើងដោយការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ ជាសារសម្លេងចេញពីខ្សែរអាត់ថត ចម្លង និង បោះពុម្ពដោយរក្សាសិទ្ធពីភាសារអង់គ្លេស។ ការបក ប្រែជាភាសារខ្មែរនេះ គឺត្រូវបោះពុម្ព និង ចែកចាយដោយ សម្លេងព្រះជាម្ចាស់ដែលបានថតទុក។

KHMER

©2021 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS
P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.
www.branham.org

# ការរក្សាសិទ្ធ

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវែបសាយ លក់តាមប្រព័ន្ធអេលេចត្រូនីក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖

វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG